បាឋកថាពិសេស

របស់

លោកជំទាវ គឹម សេដ្ឋានី

រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា

ស្តីពី *"តួនាទីនៃការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា"*

ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៥

- *នាងខ្ញុំសូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាទីគោរព !*
- *សូមគោរព ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង!*
- *សូមគោរព លោក លោកស្រី ដែលជានាយក នាយិកា គណៈគ្រប់គ្រង គ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ ទាំងអស់ជាទីស្រឡាញ់រាប់អាន!*

ថ្ងៃនេះខ្ញុំមានកិត្តិយសដើម្បីមកធ្វើបទឧទ្ទេសពិសេសមួយ ពាក់ព័ន្ធនឹង **"តួនាទីនៃការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា"** ។

មូលហេតុអ្វីបានជាកំណែទម្រង់វិស័យអប់រំនៅកម្ពុជាចាំបាច់ត្រូវចាប់ផ្តើមពីការលើកកម្ពស់គុណភាពសេវាអប់រំកុមារតូច ?

បទឧទ្ទេសនាមរបស់នាងខ្ញុំចែកចេញជាបីផ្នែក៖ ទី១).ការអប់រំកុមារតូច និងបដិវត្តន៍ឧស្សាហកម្មទីបួន ទី២). ស្ថានភាពនៃការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅកម្ពុជា និងទី៣). កំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា និងទី៤).សេចក្តីសន្និដ្ឋាន។

ផ្នែកទី១៖ ការអប់រំកុមារតូច និងបដិវត្តន៍ឧស្សាហកម្មទីបួន

ពិភពលោករបស់យើងកំពុងស្ថិតនៅដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មទីបួន។ ដោយសារតែសកលភាវូបនីយកម្ម ភាពរីកចម្រើនខាងបច្ចេកវិទ្យាត្រូវបានជំរុញ ដោយការរកឃើញថ្មីៗផ្នែកបច្ចេកវិទ្យាដែលគ្របដណ្តប់លើវិស័យជាច្រើន ដូចជា AI, IoT, ការបោះពុម្ព 3D បច្ចេកវិទ្យាមនុស្សយន្ត បច្ចេកវិទ្យាណាណូ វិទ្យាសាស្ត្រសម្ភារៈ Quantum Computing រថយន្តបើកបរដោយខ្លួនឯង និងការរក្សាទុកថាមពលជាដើម។ នេះលែងមានតែក្នុងរឿងប្រលោមលោកវិទ្យាសាស្ត្រទៀតហើយ ប៉ុន្តែវាគឺជាការពិតរួចទៅហើយ។

បដិវត្តន៍ថ្មីនេះ មានឥទ្ធិពលយ៉ាងខ្លាំងលើរបៀបដែលយើងបណ្តុះបណ្តាលមនុស្សជំនាន់ថ្មីនាពេលបច្ចុប្បន្ននេះ ដើម្បីឱ្យពួកគេត្រៀមខ្លួនសម្រាប់ទីផ្សារការងារនាពេលអនាគត។ កុមារថ្ងៃនេះ អាចនឹងធ្វើការផ្លាស់ប្តូរការងារយ៉ាងហោចណាស់ ៧ដង ក្នុងមួយជីវិតរបស់ពួកគេ ហើយការងារយ៉ាងតិចបំផុត

ចំនួន ៥ ក្នុងចំណោមការងារទាំងនេះ នៅមិនទាន់មានរូបរាងនៅឡើយ។ ដូច្នេះគេពុំអាចព្យាករដឹងទេថា តើ**ជំនាញរឹង** ណាខ្លះ ដែលកុមារកំពុងរៀនក្នុងថ្នាក់រៀននាពេលបច្ចុប្បន្ននេះនឹងត្រូវការសម្រាប់ការងារដែលពួកគេនឹងធ្វើ ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខទៀតឡើយ។ កាលពីឆ្នាំ២០១៦ ក្រុមការងារអប់រំសាកលបានរំពឹងថា នៅឆ្នាំ២០៣០ មានមនុស្សវ័យក្មេងជាងពាក់កណ្តាលនឹងមិនមានការងារធ្វើដោយហេតុថា ពួកគេមិនមានជំនាញសម្រាប់បម្រើទីផ្សារការងារដែលតែងតែមានការប្រែប្រួលយ៉ាងឆាប់រហ័ស។

World Economic Forum(2018) បង្ហាញថា៖ ដើម្បីឆ្លើយតបនឹងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបំណិនសម្រាប់សតវត្សទី២១ ការអប់រំត្រូវយកចិត្តទុកដាក់ ផ្តល់លើជំនាញជាមូលដ្ឋានគ្រឹះចំនួន ១៦ ដែលជាតម្រូវការរបស់សិស្សានុសិស្សសម្រាប់ត្រៀមបម្រើទីផ្សារពលកម្ម មានជាអាទិ៍៖ ១.សមត្ថភាព លើការសរសេរ-ការអាន ២.សមត្ថភាពលេខនព្វន្ត ៣.សមត្ថភាពផ្នែកវិទ្យាសាស្ត្រ ៤.សមត្ថភាពផ្នែកបច្ចេកវិទ្យាICT ៥.សមត្ថភាពផ្នែកហិរញ្ញវត្ថុ ៦.ការយល់ដឹងពីវប្បធម៌និងពលរដ្ឋល្អ ៧.ការគិតពិចារណានិងដោះស្រាយបញ្ហា ៨.ការច្នៃប្រឌិត ៩.ទំនាក់ទំនង ១០.ការធ្វើកិច្ចសហប្រតិបត្តិការ ១១.ការចង់ចេះចង់ដឹង ១២.គំនិតផ្តួចផ្តើម ១៣.ការតស៊ូ និងការអត់ធន់ ១៤.ការបបន្ទុំនិងការទទួលយក ១៥.ភាព ជាអ្នកដឹកនាំ និង ១៦.ការយល់ដឹងពីសង្គមនិងវប្បធម៌។

ផ្អែកតាម*ការអង្កេតលើក្រុមហ៊ុនធំៗ ចំនួន ៩០០ បានបញ្ជាក់ថា* **ជំនាញទន់** គឺជាជំនាញដែលពាក់ព័ន្ធបំផុតសម្រាប់អនាគត។ ការងារដែលសូម្បីតែបញ្ញាញាណសប្បនិម្មិត (artificial intelligence) មិនអាចជំនួសបានដៃរនោះ គឺជាការងារដែលត្រូវការបុគ្គលិកលក្ខណៈរឹងមាំរបស់មនុស្ស។

បើផ្អែកតាម លោក Garcia and Heckman (2021) អន្តរាគមន៍កុមារក្នុងវ័យដំបូងមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍមូលធនជំនាញមិនមែនពុទ្ធិបញ្ញា (Non-Cognitive capital) និងជំនាញមូលធនពុទ្ធិបញ្ញា (Cognitive capital)។ អ្នកសិក្សាស្រាវជ្រាវបានរកឃើញថាជំនាញមិនមែនពុទ្ធិបញ្ញា ដូចជាការចេះលត់ដំខ្លួនឯង ការតស៊ូ ការជឿជាក់ និងចរិតលក្ខណៈផ្ទាល់ខ្លួន ដូចជាភាពជាអ្នកដឹកនាំ គឺនាំមកនូវភាពជោគជ័យក្នុងជីវិត។ **មនុស្សដែលមានភាពឆ្លាតផ្នែកបញ្ញា(IQ)ខ្ពស់ ប្រហែលជាមិនទទួលបានជោគជ័យក្នុងជីវិតទេ ប្រសិនបើពួកគេមិនមានចរិតលក្ខណៈមួយចំនួនដូចជា ភាពអំណត់និងការតស៊ូព្យាយាមជាដើម។ ដូច្នេះការអភិវឌ្ឍជំនាញនៅវ័យជាទារកនិងកុមារតូច មានសារៈសំខាន់យ៉ាងខ្លាំង នៅពេលដែលសមត្ថភាពនិងការលើកទឹកចិត្តរបស់មនុស្សត្រូវបានកំណត់ដោយកត្តាគ្រួសារនិងកត្តាមជ្ឈដ្ឋានជុំវិញ។** ការរៀនសូត្រក្រោយការបញ្ចប់ការសិក្សានៅសាលារៀន ពោលគឺការធ្វើបណ្តើររៀនបណ្តើរ និងការរៀននៅកន្លែងធ្វើការងារ ជួយបង្កើតជំនាញពីមួយភាគបី ទៅមួយភាគពីរ ក្នុងសេដ្ឋកិច្ចសម័យទំនើប។

ដូច្នេះការអភិវឌ្ឍកុមារតូចផ្តល់មូលដ្ឋានគ្រឹះសម្រាប់បំណិនបញ្ញាញាណផង និងបំណិនដែលមិនពាក់ព័ន្ធជាមួយបញ្ញាញាណ ដូចជាការរៀនសូត្រពេញមួយជីវិត និងបំណិនសម្រាប់សតវត្សរ៍ទី២១ជាដើម

ដែលសុទ្ធតែជាបំណិនដែលនឹងអភិវឌ្ឍនាពេលក្រោយៗទៀត។ (World Bank, 2011; García, & Heckman, 2021; Walker, et al., 2022)

ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការគាំពារនិងអភិវឌ្ឍន៍កុមារតូច នៅក្នុងឆ្នាំដំបូងៗ គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍនៅពេលបន្តបន្ទាប់ទៀតក្នុងដំណើរជីវិតរបស់ពួកគាត់ (Yoshikawa, et al., 2013)។ ការវិនិយោគលើធនធានមនុស្សសម្រាប់កុមារស្ថិតក្នុងវ័យចូលរៀននៅមត្តេយ្យសិក្សា គឺផ្តល់នូវផលត្រឡប់មកវិញខ្ពស់បំផុត (World Bank, 2010; Yoshikawa, et al., 2013; Walker, et al., 2022) ។ ការវិនិយោគប្រកបដោយប្រសិទ្ធភាពក្នុងការគាំពារនិងអភិវឌ្ឍកុមារតូច នឹងអាចកាត់បន្ថយនូវវិសមភាពដែលកើតចេញពីភាពក្រីក្រ កង្វះអាហារូបត្ថម្ភ និងឱកាសរៀនសូត្រ (Engle et al. 2011; Sierens, et al., 2020; Zambrana, et al., 2020) ។

ក្រសួងអប់រំ យុវជន និងកីឡាមានវត្តុបំណងគោលនយោបាយក្នុងការពង្រីកសេវាអប់រំកុមារតូចប្រកបដោយគុណភាពនៅទូទាំងប្រទេស និងការប្តេជ្ញាចិត្តបង្កើនអត្រារួមនៃកុមារអាយុ ៣ឆ្នាំទៅ ៥ឆ្នាំឱ្យទទួលបានសេវាអប់រំប្រកបដោយគុណភាព។ **ការពង្រីក និងលើកកម្ពស់គុណភាពសេវាមត្តេយ្យសិក្សាសហគមន៍ជាមធ្យោបាយមួយដែលប្រទេសកម្ពុជាអាចយកជាជម្រើសដែលប្រសើរបំផុតក្នុងការឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍អប់រំប្រកបដោយចីរភាព និងចក្ខុវិស័យអប់រំឆ្នាំ ២០៣០ ដើម្បីជានាបានការអប់រំប្រកបដោយបរិយាបន្ន សមធម៌គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ជាពិសេសក្នុងការកំណត់ចំណុចដៅត្រឹមឆ្នាំ២០៣០ ធានាថាកុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា(អ. យ. ក.,២០១៩)។**

សេវាអប់រំកុមារតូចដែលបាននិងកំពុងដំណើរការនៅកម្ពុជារួមមាន៖ មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន និងកម្មវិធីអប់រំមាតាបិតា។ សេវាមត្តេយ្យសិក្សាសហគមន៍ ត្រូវបានបង្កើតឡើងនៅតាមតំបន់គោលដៅភូមិសាស្ត្រ ដែលនៅឆ្ងាយ ឬពុំទាន់មានសាលាមត្តេយ្យសិក្សាសាធារណៈ ដើម្បីផ្តល់ឱកាសឱ្យកុមារអាយុ ៣ឆ្នាំ ទៅក្រោម ៦ឆ្នាំ ទទួលបានការសិក្សានៅកម្រិតមត្តេយ្យសិក្សាចាប់តាំងពីឆ្នាំ២០០៣ ក្រោមកិច្ចសហការរវាងក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងអប់រំយុវជន និងកីឡា ដោយមានគាំទ្រពីអង្គការដៃគូអភិវឌ្ឍនានា។

ផ្អែកតាមរបាយ-ការណ៍បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៣-២០២៤ បានបង្ហាញថា សេវាមត្តេយ្យសិក្សាសហគមន៍បានគ្របដណ្តប់ ១/៥ នៃសេវាអប់រំកុមារតូចគ្រប់រូបភាព ប៉ុន្តែមត្តេយ្យសិក្សាសហគមន៍មួយចំនួនបាននឹងកំពុងជួបប្រទះនូវបញ្ហាប្រឈមជាច្រើនពាក់ព័ន្ធគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃសេវា។

ផ្នែកទី២៖ ស្ថានភាពនៃការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅកម្ពុជា

ការលើកកម្ពស់ការអប់រំកុមារតូច គឺការកសាងនូវមូលដ្ឋានគ្រឹះសម្រាប់ការអប់រំប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងកត្តាខាងក្រៅដូចជាការផ្លាស់ប្តូរក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសក្នុងបរិបទនៃការប្រណាំងប្រជែងក្នុងពិភពលោកសម័យក្រោយជំងឺកូវីដ-១៩ បរិវត្តកម្មឌីជីថល បដិវត្តឧស្សាហកម្មទី៤ ការប្តេជ្ញាចិត្តសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងកត្តាផ្ទៃក្នុងផង ដូចជាការការពារសិទ្ធិកុមារដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាតព្វកិច្ចក្នុងច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការអនុវត្តគោលនយោបាយវិមជ្ឈការក្នុងវិស័យអប់រំជាដើម។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ បានកំណត់ថា ***«រដ្ឋធានាការការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ និងសិទ្ធិទទួលបានការអប់រំរៀនសូត្រ»***។

ច្បាប់ស្តីពីការអប់រំ មាត្រា១៦ បានកំណត់ថា ***«រដ្ឋត្រូវគាំពារ និងអប់រំកុមារតូចចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សាដែលជាទូទៅប្រព្រឹត្តនៅ ទារកដ្ឋាន នៅសហគមន៍ ឬនៅផ្ទះ»*** ការអប់រំមត្តេយ្យសិក្សាត្រូវចាប់អនុវត្តមុនបឋមសិក្សាដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា។

កាលពីឆ្នាំ ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិស្តីពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច ហើយក្នុងឆ្នាំ ២០១៤ បានបង្កើតគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូចជាយន្តការសម្រាប់សម្របសម្រួលគ្រប់ការងារទាំងអស់ពាក់ព័ន្ធនឹងកុមារតូច និងអន្តរាគមន៍ទាំងអស់ដែលអនុវត្ត ដោយអ្នកពាក់ព័ន្ធសំខាន់ៗ។

ស្ថិតក្នុងដំណាក់កាលបច្ចុប្បន្ននៃការធ្វើកំណែទម្រង់វិស័យអប់រំរបស់កម្ពុជាការងារអប់រំ និងគាំពារកុមារតូច គឺជាអាទិភាពមួយក្នុងការផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំនិងមិនអាចខ្វះបានក្នុងការកែលម្អលទ្ធផលសិក្សារបស់សិស្សនៅគ្រប់កម្រិតសិក្សា។

ការប្តេជ្ញាចិត្តសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ប្រទេសកម្ពុជាប្តេជ្ញាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព **គោលដៅទី៤** គឺ ***« ធានាការអប់រំប្រកបដោយ គុណភាព បរិយាបន្ននិងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប»*** **ចំណុចដៅ ៤.២** បានកំណត់ត្រឹមឆ្នាំ២០៣០ ***« ធានាថាកុមារានិងកុមារីគ្រប់រូបនឹងទទួលបាននូវការអភិវឌ្ឍក្នុងភាពជាកុមារតូចទាំងការថែរក្សា និងការអប់រំនៅមត្តេយ្យសិក្សា ប្រកបដោយគុណភាព សម្រាប់ត្រៀមខ្លួនគ្រប់គ្រាន់សិក្សានៅកម្រិតបឋមសិក្សា»*** ។

ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (SDG4) ដែលជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) របស់អង្គការសហប្រជាជាតិ បានបញ្ជាក់ពីដំណាក់កាលថ្មីមួយទៀត នៃការអភិវឌ្ឍវិស័យអប់រំឆ្លើយតបនឹងបរិបទសកលលោកដែលមានមហិច្ឆតានិងវិសាលភាពធំជាងមុន សំដៅលើកកម្ពស់គុណភាព ប្រកបដោយសមធម៌ បរិយាបន្ន

និងការសិក្សាពេញមួយជីវិត។ សមិទ្ធផលអប់រំ និងឧត្តមានុវត្តន៍ជាច្រើននៅកម្ពុជាបានទទួលពីការអនុវត្ត គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា ជាមូលដ្ឋានដ៏សំខាន់ឈានទៅ សម្រេចការអប់រំក្នុងបរិបទ ឆ្នាំ២០៣០ ខាងមុខ។

ក្នុងរយៈពេល១០ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និង២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ ដូចជា ការបង្កើនការចូលរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ននៅគ្រប់ភូមិសិក្សា ការពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា ការយកចិត្តទុកដាក់លើគ្រូបង្រៀន និងការដោះស្រាយការខាតបង់ការសិក្សាក្នុងបរិបទកូវីដ-១៩។ ក្រសួងបានសម្រួចវិធានការពាក់ព័ន្ធក្នុងគោលដៅលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំ តាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការលើកទឹកចិត្តបុគ្គលិកអប់រំ ការបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំនៅគ្រប់លំដាប់ថ្នាក់។ ជាមួយគ្នានេះ ក្រសួងក៏បានឆ្លើយតបនឹងការអនុវត្តកំណែទម្រង់របស់រាជរដ្ឋាភិបាលសំខាន់ៗ ដូចជាកំណែទម្រង់រឹមជ្រការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការកសាងសមត្ថភាពស្ថាប័នផងដែរ។

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលអាណត្តិទី៧នៃរដ្ឋសភា ក្រោមការដឹកនាំរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានកំណត់ **មនុស្ស** ជាអាទិភាពទីមួយ នៅក្នុងបញ្ចកោណទី១ បានលើកឡើងអំពី ***"ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា"***។ ឈរលើមូលដ្ឋាននេះ ក្រសួងបានកំណត់អាទិភាពចំនួនប្រាំបី៖ **១.**ការពង្រឹងអភិបាលកិច្ចសាលារៀន **២.**ការពិនិត្យនិងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពបន្ថែមក្រៅម៉ោងសិក្សាស្របតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងអាកប្បកិរិយារបស់សិស្ស **៣.**ការថែរក្សាសុខភាពសិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភរបស់កុមារ និងការគ្រប់គ្រងគុណភាពអាហារនៅតាមសាលារៀន **៤.**ការជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងវិស័យអប់រំ ស្របពាក្យស្លោក **« ភាពជាដៃគូរដ្ឋ និងសហគមន៍ក្នុងការអប់រំ»** **៥.**ការពង្រឹងការអប់រំឌីជីថល **៦.**ការជំរុញមជ្ឈមណ្ឌលឧត្តមភាព ក្នុងការអប់រំឧត្តមសិក្សា **៧.**ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព និង **៨.** ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ បានបង្រួមខ្លឹមសារគោលនយោបាយអប់រំឱ្យនៅតែមួយគឺ ***« ជានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត»***។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរៀនសូត្ររបស់កុមារតូចកម្ពុជា ក្រសួងអប់រំ យុវជននិងកីឡា បានខិតខំបង្កើតមតេ្តយ្យសិក្សាគ្រប់រូបភាព (មតេ្តយ្យសិក្សាសាធារណៈ មតេ្តយ្យសិក្សាសហគមន៍ និងមតេ្តយ្យ

សិក្សាឯកជន) និងពង្រីកសេវាអប់រំកុមារតូចនៅគ្រប់ទីកន្លែង ក្នុងន័យធ្វើឱ្យសាលារៀនកាន់តែខិតជិតផ្ទះប្រជាពលរដ្ឋងាយស្រួលក្នុងការផ្តល់ និងទទួលសេវាអប់រំផងដែរ។

ក. បង្កើនការចូលរៀនរបស់កុមារអាយុពី ០ ដល់ ៦ ឆ្នាំ ៖

(ទី១). លទ្ធផលសម្រេចបានក្នុងរយៈពេល ១០ ឆ្នាំ (២០១៣ ដល់ ២០២៣)

អត្រារួមនៃការសិក្សាកុមារអាយុ ៥ ឆ្នាំ គ្រប់រូបភាព បានបង្ហាញពីវឌ្ឍនភាពក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ កុមារអាយុ ៥ ឆ្នាំ បានចុះឈ្មោះចូលរៀនក្នុងការអប់រំកុមារតូចគ្រប់រូបភាព បានកើនឡើងពី ៥៩,៩ ភាគរយ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៦៤,៨ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ អត្រាចូលរៀនមានវឌ្ឍនភាពនៅចន្លោះឆ្នាំ២០១៥ និង២០១៩ និងបានធ្លាក់ចុះក្នុងរយៈពេល ៣ឆ្នាំ ជាប់ៗគ្នា ពីឆ្នាំ២០១៩ ដល់ ២០២២ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។

រូបភាព ១ ៖ អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)



ប្រភព៖ ប្រព័ន្ធព័ត៌មាននាយកដ្ឋានអប់រំកុមារតូច

អត្រារួមនៃការសិក្សារបស់កុមារអាយុ៣-៥ឆ្នាំ កើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ បានកើនឡើងពី ៣៣,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៣៧,១ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ និន្នាការនេះ បង្ហាញថាអត្រារួមនៃការសិក្សាបានកើនឡើង ៣,៧ ភាគរយ។

រូបភាព ២៖ អត្រារួមនៃការសិក្សាកុមារអាយុ ៣-៥ ឆ្នាំ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)



ប្រភព៖ ប្រព័ន្ធព័ត៌មាននាយកដ្ឋានអប់រំកុមារតូច

(ទី២). លទ្ធផលសម្រេចបានក្នុងឆ្នាំសិក្សា២០២៤-២០២៥

សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៩ ០៣៦សាលា/កន្លែង មានទីតាំង ១ ១១៩ ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៥២ ឃុំ សង្កាត់។ សាលាមត្តេយ្យសិក្សាសាធារណៈមាន ៤ ៧២៥ ក្នុងនោះសាលាមត្តេយ្យសិក្សាដាច់ដោយឡែក ៣៨០។ សាលាឯកជនដែលមានកម្រិតមត្តេយ្យសិក្សា ចំនួន ៩៦៣ កន្លែង មត្តេយ្យសិក្សាសហគមន៍ ៣ ៣៤៨កន្លែង ។

រូបភាពទី៣ ស្ថិតិសាលាមត្តេយ្យសិក្សាគ្រប់រូបភាពឆ្នាំសិក្សា២០២៣-២០២៤



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

កុមារទទួលបានសេវាអប់រំគ្រប់រូបភាព ៤២៥ ៥៣៩នាក់ ស្រី ២១១ ៩១៣នាក់។ កុមារអាយុ ៣ឆ្នាំមាន ៥៦ ៤៨៧នាក់ ស្រី ២៩ ០១២នាក់។ កុមារអាយុ ៤ឆ្នាំមាន ១៣៨ ៨៦៨នាក់ ស្រី ៦៩ ៧១០ នាក់ និង កុមារអាយុ ៥ឆ្នាំមាន ២៣០ ១៨៤នាក់ ស្រី ១១៣ ១៩១នាក់។

រូបភាពទី៤ ៖ ស្ថិតិកុមារមត្តេយ្យសិក្សាតាមកម្មវិធី



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

អត្រាចុះឈ្មោះចូលរៀនរបស់កុមារទទួលបានសេវាអប់រំគ្រប់រូបភាពមាន៖ កុមារអាយុ ៥ឆ្នាំ ៧១,៤ភាគរយ ស្រី ៧១,៩ភាគរយ។ កុមារអាយុ ៤ឆ្នាំ ៤៣,១ភាគរយ ស្រី ៤៤,៣ភាគរយ។ កុមារអាយុ ៣ឆ្នាំ ១៦,៧ភាគរយ ស្រី ១៧,៦ភាគរយ ។

រូបភាពទី៦ ៖ អត្រាកុមារមត្តេយ្យសិក្សាតាមអាយុ



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សាគ្រប់រូបភាពមានវឌ្ឍនភាពប្រែប្រួលខ្លាំងគួរឱ្យកត់សម្គាល់។ អត្រារួមនៃការសិក្សាកុមារអាយុ ៣ ទៅ ៥ឆ្នាំ មាន ៤៣ភាគរយ កើន ៤,៤ភាគរយ ស្រី ៤៣,៨ភាគរយ កើន ៣,៩ភាគរយ។

រូបភាពទី៧ ៖ អត្រាចូលរៀនកុមារអាយុ ៣ ទៅ ៥ឆ្នាំ



ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០២៤-២០២៥ ខេត្តដែលបានផ្តល់សេវាអប់រំកុមារតូចអាយុ៥ឆ្នាំ គ្រប់រូបភាពខ្ពស់ជាងថ្នាក់ជាតិជាក់ស្តែង(៧១.៤%) ពី ៧៣.៤ភាគរយ រហូតដល់៩៨.៥ភាគរយមានចំនួន ១១ខេត្តគឺខេត្តកោះកុង ព្រះសីហនុ សៀមរាប តាកែវ ពោធិ៍សាត់ កំពង់ចាម កែប ភ្នំពេញ កំពង់ឆ្នាំង កំពង់ស្ពឺ និងបាត់ដំបង។ ស្ថានភាពនៃការចូលរៀនកុមារអាយុ៥ឆ្នាំ នៅមត្តេយ្យសិក្សារដ្ឋ ឯកជន និងមត្តេយ្យសិក្សាសហគមន៍ទាំង១១ រាជធានីខេត្តខ្ពស់ជាងគេ ដោយសារ មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍កាន់តែមានការជឿជាក់ទុកចិត្ត ចូលរួមគាំទ្រអភិបាលកិច្ចសាលារៀន និងយល់កាន់តែច្បាស់ពីសារៈសំខាន់នៃការអប់រំកុមារតូច។ ដោយឡែក មានខេត្តចំនួន៣ មានភាគរយខាងលើទាបជាងគេគឺខេត្តស្ទឹងត្រែង មណ្ឌលគិរី និងព្រះវិហារ។ ដូចនេះខេត្តទាំង៣ ខាងលើនេះ ត្រូវយកចិត្តទុកដាក់លើការពង្រីកសេវាអប់រំកុមារតូចគ្រប់រូបភាពឱ្យបានទូលំទូលាយបន្ថែមទៀត ជាពិសេសពង្រីកថ្នាក់មត្តេយ្យក្នុងបឋមសិក្សា និងមត្តេយ្យសិក្សាសហគមន៍។ ចំនួនក្រុង ស្រុក ខណ្ឌ ដែលមានភាគរយកុមារចូលរៀនអាយុ៥ឆ្នាំតាមក្រុង ស្រុក ខណ្ឌ ឆ្នាំសិក្សា២០២៤-២០២៥ ខ្ពស់ជាងថ្នាក់ជាតិជាក់ស្តែង (៧១.៤%) ឡើងទៅមានចំនួន១០០ ក្រុង ស្រុក ខណ្ឌ

រូបភាពទី៨៖ ភាគរយកុមារចូលរៀនអាយុ៥ឆ្នាំ តាមរាជធានី ខេត្តឆ្នាំសិក្សា ២០២៤-២០២៥



ក្នុងឆ្នាំសិក្សា២០២៤-២០២៥ ភាគរយកុមារចូលរៀននៅបឋមសិក្សាបានឆ្លងកាត់ការអប់រំកុមារតូចមានចំនួន ៧៩,៦ភាគរយ។

ខ. ការផ្តោតការយកចិត្តទុកដាក់លើការអប់រំបរិយាបន្ន ជាពិសេសសម្រាប់កុមារក្រីក្រ កុមារជនជាតិភាគតិច និងកុមារពិការ ៖

កម្មវិធីអប់រំពហុភាសា និងកម្មវិធីអប់រំបរិយាបន្ន ចាំបាច់ត្រូវតែទទួលបានអាទិភាព ក្រសួងក៏មានគំនិតផ្តួចផ្តើមផ្សេងៗក្នុងគោលបំណងលើកកម្ពស់ការចូលរៀនក្នុងការអប់រំកុមារតូចសម្រាប់កុមារជនជាតិដើមភាគតិច ដែលភាគច្រើនមានទីតាំងនៅតំបន់ភាគឦសាន។ នៅឆ្នាំសិក្សា២០២៤-២០២៥ កម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច (ទំពួន គ្រឹង ព្នង កួយ ក្រោល ការ៉ែត ព្រៅ ចារ៉ាយ និងកាចក់) បានអនុវត្តនៅតាមសាលាមត្តេយ្យសិក្សារដ្ឋ ៤កន្លែង មានកុមារ ១៤៦នាក់ ស្រី ៧៨ នាក់ និងមត្តេយ្យសិក្សាសហគមន៍ ១៥៤កន្លែង មានកុមារ ២ ៨៧១នាក់ ស្រី ១ ៤៧១នាក់ នៅ ២១ ក្រុង ស្រុក ក្នុងខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ និងខេត្តព្រះវិហារ

កុមារមានពិការភាពនៅសាលាមត្តេយ្យសិក្សាសាធារណៈទូទាំងប្រទេសមាន ៧២០នាក់ ស្រី ២៨៦ នាក់ ក្នុងនោះទទួលបានការគាំទ្រសេវាការអប់រំបរិយាបន្ន ៤៤,៥៨ ភាគរយ ។ កុមារមានពិការភាពនៅមត្តេយ្យសិក្សាសហគមន៍ចំនួន ២៤០នាក់ ស្រី ១០៦នាក់ ក្នុងនោះទទួលបានការគាំទ្រសេវាការអប់រំបរិយាបន្ន ៥៨ភាគរយ ក្នុងសាលាគោលដៅនៅខេត្តសៀមរាប កំពង់ធំ រតនគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រៃវែង ព្រះសីហនុ ឧត្តរមានជ័យ និងរាជធានីភ្នំពេញ។ អនុវត្តកម្មវិធីអប់រំពិសេសនៅវិទ្យាល័យអប់រំពិសេស ៦ សាលា ក្នុងនោះកម្រិតមត្តេយ្យសិក្សា ២០៩នាក់ ស្រី ៤៧ នាក់ នៅខេត្តកណ្តាល កំពង់ចាម សៀមរាប បាត់ដំបង និងរាជធានីភ្នំពេញ។

គ. ការគាំពារ និងអភិវឌ្ឍន៍កុមារតូចក្នុងរយៈពេល ១000 ថ្ងៃដំបូងនៃជីវិត

ការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្លើយតបជាមួយអំឡុងរយៈពេលចន្លោះ ចាប់ពីបដិសន្ធិរហូតដល់អាយុក្រោម ៦ឆ្នាំ ពេលដែលខួរក្បាលកុមារកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍដ៏មានសារៈសំខាន់បំផុតពិសេស រយៈពេល ១.000 ថ្ងៃដំបូងក្នុងជីវិត។ ក្នុងអំឡុងពេលនេះតំណភ្ជាប់ប្រព័ន្ធប្រសាទត្រូវបានកំណត់រូបរាងដោយបន្សំរវាងបទពិសោធន៍ជីវិត ជាមួយកត្តាផ្នែកបរិស្ថាន បូកផ្សំជាមួយអាហារូបត្តម្ភល្អ ការថែទាំសុខភាព និងបរិស្ថានផ្ទះសម្បែងមានសុវត្ថិភាព និងមានការភ្ញោចបានល្អនោះ នាំឲ្យកុមារអាចរៀនសូត្រ និងលូតលាស់ដើម្បីឈានសម្រេចបានសក្តានុពលមានតែមួយគត់របស់ខ្លួន (United Nations Children's Fund, 2017)។

អំឡុងពេលចាប់ពីមានផ្ទៃពោះរហូតដល់អាយុបីឆ្នាំ គឺជារយៈពេលដ៏មានសារៈសំខាន់បំផុតជាពេលដែលខួរក្បាលលូតលាស់លឿនជាងពេលណាៗទាំងអស់។ ៨0%នៃខួរក្បាលរបស់ទារកត្រូវបានបង្កើតឡើងក្នុងអំឡុងពេលនេះ។ បទពិសោធក្នុងជីវិតកុមារតូច មានផលប៉ះពាល់ដ៏ជ្រាលជ្រៅទៅលើការអភិវឌ្ឍរបស់កុមារ។ បទពិសោធនេះ ជះឥទ្ធិពលដល់ការរៀនសូត្រ សុខភាព អាកប្បកិរិយា ព្រមទាំងទំនាក់ទំនងសង្គមក្នុងពេលពេញវ័យ សុខុមាលភាព និងការរកកម្រៃផងដែរ។ អំឡុងពេលចាប់ពីមានផ្ទៃពោះរហូតដល់អាយុបីឆ្នាំ ជាពេលដែលកុមារងាយរងឥទ្ធិពលពីបរិស្ថានជុំវិញខ្លាំងបំផុត។ ដើម្បីឱ្យ

ខួរក្បាលមានការអភិវឌ្ឍល្អក្នុងអំឡុងពេលប៉ុន្មានឆ្នាំដំបូងនេះ កុមារត្រូវការបរិស្ថានមានសុវត្ថិភាព មានសន្តិសុខ និងប្រកបដោយក្តីស្រលាញ់ មានអាហារូបត្ថម្ភ និងការភ្ញោចត្រឹមត្រូវពីមាតាបិតា ឬអ្នកថែទាំរបស់ខ្លួន។ ហេតុនេះក្របខ័ណ្ឌការងារការថែទាំដោយមានការទំនុកបម្រុងរួមមានសមាសភាគចំនួនប្រាំ៖ ១.សុខភាពល្អ ២.អាហារូបត្ថម្ភគ្រប់គ្រាន់ ៣.ការថែទាំដោយមានលក្ខណៈឆ្លើយតប ៤.សុវត្ថិភាពនិងសន្តិសុខ និង ៥.ឱកាសទទួលបានការរៀនសូត្រតាំងពីដំបូង (United Nations Children's Fund, 2017)។

រូបភាពទី៨ ៖ ក្របខ័ណ្ឌការងារការថែទាំកុមារតូចដោយមានការទំនុកបម្រុង

តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** សម្តេចបានស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធសហការគ្នាបង្កើតទារកដ្ឋានសហគមន៍រោងចក្រសហគ្រាស សម្រាប់កូនកម្មករកម្មការិនីអាយុពី ៣ខែ ដល់ក្រោម ៣ឆ្នាំ ទទួលបានសេវាថែទាំ គាំពារ និងអភិវឌ្ឍប្រកបដោយជំនាញវិជ្ជាជីវៈ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងនាមជាស្ថាប័នដឹកនាំ បានកំណត់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងការអប់រំកុមារតូច ផ្តោតលើការបង្កើតកម្មវិធីទារកដ្ឋានសហគមន៍រោងចក្រសហគ្រាសជាអាទិភាពមួយក្នុងចំណោមការងារអាទិភាពនានា។ ជាក់ស្តែងក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការពិភពកុមារ និងអភិវឌ្ឍ(PE&D) ក្រោមការគាំទ្រថវិកាពីធនាគារពិភពលោក បានរួមគ្នារៀបចំបង្កើតទារកដ្ឋានផ្តល់សេវាថែទាំ គាំពារ និងអភិវឌ្ឍប្រកបដោយវិជ្ជាជីវៈបានចំនួន ១៣កន្លែង នៅខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម។ ដោយឡែកក្រសួងការងារបាននឹងកំពុងរៀបចំទារកដ្ឋាននៅតំបន់សេដ្ឋកិច្ចពិសេស ចំនួន ៣កន្លែង (រាជធានីភ្នំពេញ ១កន្លែង កំពង់ស្ពឺ ១កន្លែង និងខេត្តកំពង់ឆ្នាំង ១កន្លែង)។

ផ្នែកទី៣៖ កំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

នៅក្នុងដំណើរការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងសេវាអប់រំកុមារតូចនៅឆ្នាំ២០០៣ ក្រោមកិច្ចសហការរវាងក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីអង្គការដៃគូអភិវឌ្ឍនានា មត្តេយ្យសិក្សាសហគមន៍ត្រូវបានបង្កើតឡើងនៅតាមតំបន់គោលដៅភូមិសាស្ត្រដែលនៅឆ្ងាយ ឬពុំទាន់មានសាលាមត្តេយ្យសិក្សាសាធារណៈគ្របដណ្តប់ ដើម្បីផ្តល់ឱកាសឱ្យកុមារដែលមានអាយុ ចាប់ពី៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។ មត្តេយ្យសិក្សាសហគមន៍ សំដៅដល់មណ្ឌល ឬថ្នាក់មត្តេយ្យសិក្សានៅតាមឃុំសង្កាត់ដោយប្រើប្រាស់នូវមូលនិធិរបស់ឃុំ សង្កាត់ ឬបានទទួលការគាំទ្រមូលនិធិពីដៃគូអភិវឌ្ឍ ឬសប្បុរសជននានា។ រដ្ឋបាលឃុំ សង្កាត់អាចប្រើប្រាស់មូលនិធិរបស់ខ្លួន សម្រាប់រៀបចំដំណើរការមត្តេយ្យសិក្សាសហគមន៍។ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានគម្រោងបង្កើតមត្តេយ្យសិក្សាសហគមន៍ថ្មីត្រូវធានាលក្ខខណ្ឌតម្រូវដូចជា៖(១)ទីតាំងមត្តេយ្យសិក្សាសហគមន៍ ត្រូវស្ថិតនៅតំបន់ដែលឆ្ងាយពីសាលា/ថ្នាក់មត្តេយ្យសិក្សារដ្ឋ ឬស្ថិតនៅតំបន់ជួបការលំបាក សម្រាប់កុមារតូចក្នុងការទទួលបានសេវាអប់រំ (២) ទីតាំងមត្តេយ្យសិក្សាសហគមន៍ ត្រូវមាន ទីធ្លាសមស្រប មានអនាម័យ មានសុវត្ថិភាព មានបង្គន់ និងទឹកស្អាតសម្រាប់ប្រើប្រាស់ មានកន្លែងលាងដៃ និង(៣)មានបំពាក់សម្ភារបរិក្ខារៈ និងធនធានសិក្សា និងមានកន្លែងសម្រាប់កុមាររលេងក្រៅថ្នាក់យ៉ាងតិចមួយប្រភេទ ដែលកុមារអាចលេងបានជាប្រចាំ។

ចាប់ពីឆ្នាំ២០០៣មកចំនួនសាលាមត្តេយ្យសិក្សាសហគមន៍មានការកើនឡើងជាលំដាប់រហូតដល់ជិត ៣ ៥០០កន្លែង នៅឆ្នាំ ២០១៣ ។ ប៉ុន្តែចាប់ពីឆ្នាំ ២០១៣ មកមត្តេយ្យសិក្សាសហគមន៍ជាច្រើនត្រូវបានបិទទ្វារ ដោយសារគម្រោងថវិកាដែលគាំទ្រដំណើរការមត្តេយ្យសិក្សាសហគមន៍របស់ដៃគូអភិវឌ្ឍជាច្រើនត្រូវបានបញ្ចប់។

ក. ស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍

នៅក្នុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សំដៅប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ចំនួនប្រមាណ ៣ ០០០ កន្លែង ដែលជាទូទៅរៀបចំបង្កើត និងគាំទ្រដោយដៃគូអភិវឌ្ឍនិងសហគមន៍ បន្តនិរន្តរភាពនៃការផ្តល់សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព ដោយបានកំណត់នូវធនធាននានាសម្រាប់គាំទ្រដល់កិច្ចដំណើរការ និងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ ព្រមទាំងស្តង់ដាអប្បបរមារបស់មត្តេយ្យសិក្សាសហគមន៍ ។

ដើម្បីអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឱ្យមានស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ដែលជាមូលដ្ឋាននៅក្នុងការ

ជួយរដ្ឋបាលឃុំ សង្កាត់ និងគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ ស្វ័យវាយតម្លៃ និងពង្រឹងការអនុវត្តខ្លួនឯង ។ ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ជាខ្នាតគំរូមួយសម្រាប់កំណត់វិសាលភាព និងវាស់វែងកម្រិតអនុវត្តនៃថ្នាក់មត្តេយ្យសិក្សាសហគមន៍ ក្នុងការធានាបាននូវប្រសិទ្ធភាព និងគុណភាពអប់រំ ស្របតាមស្ថានភាព និងបរិបទរបស់កម្ពុជា។ ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ដើម្បីធានាពីដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ ត្រូវបានកំណត់ជា ៦ផ្នែកដូចខាងក្រោម (អ.យ.ក., ២០១៨)៖

ស្តង់ដាទី១ ៖ កំណត់អំពីការធ្វើផែនការ និងការពិនិត្យតាមដាន

មាន ៦ សូចនាករ ដែលផ្តោតសំខាន់ទៅលើថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានផែនការ និងការពិនិត្យតាមដានពីអ្នកពាក់ព័ន្ធក្នុងការផ្តល់ជំនួយដល់គ្រូលើផ្នែកបច្ចេកទេសបង្រៀន ការផលិតសម្ភារៈបង្រៀននិងរៀន ការងាររដ្ឋបាល ជំនួយស្មារតី ដោះស្រាយបញ្ហាសង្គម អនាម័យ សុខភាព ចំណីអាហារ និងបញ្ហាផ្សេងទៀត តាមរយៈការប្រជុំប្រចាំសប្តាហ៍បានទៀងទាត់ ដែលនឹងអាចជួយដល់ការអភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍។

ស្តង់ដាទី២៖ កំណត់អំពីការបង្រៀន និងរៀន

ការបង្រៀន និងរៀន មាន ១២សូចនាករ ផ្តោតលើការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព ប្រការនេះ គ្រូត្រូវមានផែនការបង្រៀនគ្រប់មុខវិជ្ជា ការអនុវត្តតាមកម្មវិធីសិក្សាបានទៀងទាត់ ការបង្រៀនដោយមានការប្រើប្រាស់សម្ភារៈបង្រៀនស្របតាមខ្លឹមសារនៃមេរៀន។ គ្រូបានរៀបចំសៀវភៅ និងបញ្ជីរដ្ឋបាលត្រឹមត្រូវតាមការណែនាំ និងធ្វើការវាយតម្លៃការសិក្សារបស់កុមារអាយុ ៥ឆ្នាំ បានទៀងទាត់ ៣ដងក្នុង ១ឆ្នាំ។

ស្តង់ដាទី៣៖ កំណត់អំពីការគ្រប់គ្រងទូទៅ

ការគ្រប់គ្រងទូទៅ មាន ៥សូចនាករ ផ្តោតលើការគ្រប់គ្រងទូទៅឱ្យមានដំណើរការ និងមានប្រសិទ្ធភាព។ ក្នុងផ្នែកនេះ សំដៅលើការបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ដែលមានសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ជាប្រធាន ការអនុវត្តតួនាទី ភារកិច្ច របស់គណៈកម្មការក្នុងការវាយតម្លៃការអនុវត្តរបស់គ្រូបង្រៀន ការផ្តល់ជំនួយជាអាទិភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់បានជួយជាពិសេសការងារគ្រប់គ្រងដំណើរការថ្នាក់។

ស្តង់ដាទី៤៖ កំណត់អំពីការរាយការណ៍ និងព័ត៌មានត្រឡប់

ការរាយការណ៍ និងព័ត៌មានត្រឡប់ មាន ៤ សូចនាករ។ ការរាយការណ៍ និងផ្តល់ព័ត៌មានត្រឡប់ត្រូវបានអនុវត្តតាមគំរូពេញលេញផ្ញើទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានទាន់ពេល មានទិន្នន័យត្រឹមត្រូវ និងមានបច្ចុប្បន្នភាព។

ស្តង់ដាទី៥៖ កំណត់អំពីទីធ្លា និងសម្ភារៈល្បែងលេងក្រៅថ្នាក់

ទីធ្លា និងសម្ភារៈល្បែងក្រៅថ្នាក់ មាន៤ សូចនាករ។ ថ្នាក់មត្តេយ្យសិក្សាសហគមន៍ត្រូវមានទីតាំងស្ថិតនៅលើដីសាធារណៈ ដោយមានកម្មសិទ្ធត្រឹមត្រូវ ការរៀបចំទីធ្លាឱ្យសមស្របនឹងចំនួនកុមារ សម្ភារៈ

ល្បែងក្រៅថ្នាក់ ត្រូវធ្វើជានាថាមានសុវត្ថិភាពសម្រាប់កុមារ មានអនាម័យ មានសោភ័ណភាព អាចឱ្យកុមារលេងជាប្រចាំ និងមិនបង្កគ្រោះថ្នាក់ដល់កុមារ ដូចជា ជាច់ខ្សែ របូតខ្លៅ ច្រេះស៊ី ជាដើម។ គ្រប់កន្លែងដែលមានសម្ភារៈល្បែងលេងក្រៅថ្នាក់ត្រូវមានកៅស៊ូក្រាស់ទន់ ឬចាក់ដីខ្សាច់ ឬដាំស្មៅ។ មានបង្គន់អនាម័យអាចប្រើប្រាស់ជាប្រចាំ ដោយបែងចែកសម្រាប់កុមារា កុមារី និងមានជម្រាលសម្រាប់កុមារពិការ។

ស្តង់ដាទី៦៖ កំណត់អំពីសម្ភារៈប្រើប្រាស់ និងសង្ហារឹម

ហេដ្ឋារចនាសម្ព័ន្ធ និងសង្ហារឹម មាន ២ សូចនាករ។ ផ្នែកនេះផ្តោតទៅលើសម្ភារៈប្រើប្រាស់ និងសង្ហារឹមដែលមានលក្ខណៈសមស្របទៅនឹងវ័យរបស់កុមារ ចៀសវាងការប្រើប្រាស់សម្ភារៈតុ កៅអី សិស្សសាលាបឋមសិក្សា។ ការរៀបចំដាក់តាំងត្រឹមត្រូវទៅគ្រប់តាមជ្រុងថ្នាក់រៀន។

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ក្លាយជាឯកសារដ៏មានប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធប្រើប្រាស់ ជាថ្នាលគំរូក្នុងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍នៅតាមរដ្ឋបាល ឃុំ សង្កាត់។ ការវាយតម្លៃលើការអនុវត្តកម្រិតសូចនាករ ទាំង ៣៣ជាការដាក់ពិន្ទុផ្អែកលើភស្តុតាងនៃសូចនាកនីមួយៗដែលមានពិន្ទុសរុប ៣៣ ពិន្ទុ ស្មើនឹង១០០%។ ការកំណត់ថា (១)មានស្តង់ដាពេញលេញ (២)មានលក្ខណៈស្តង់ដា ឬ(៣)មិនទាន់មានលក្ខណៈស្តង់ដា ត្រូវបានកំណត់ដូចខាងក្រោម៖

- ប្រសិនបើថ្នាក់មត្តេយ្យសិក្សាសហគមន៍អនុវត្តលទ្ធផលសម្រេចបានចាប់ពី ៩០% ឡើងទៅ នឹងចាត់ទុកថា **មានស្តង់ដាពេញលេញ**
- ប្រសិនបើថ្នាក់មត្តេយ្យសិក្សាសហគមន៍ អនុវត្តលទ្ធផលសម្រេចបានចាប់ពី ៦៥% ដល់តិចជាង ៩០% នឹងចាត់ទុកថា **មានលក្ខណៈស្តង់ដា**
- ប្រសិនបើថ្នាក់មត្តេយ្យសិក្សាសហគមន៍ អនុវត្តលទ្ធផលសម្រេចបានតិចជាង ៦៥% នឹងចាត់ទុកថា **មិនទាន់មានលក្ខណៈស្តង់ដា**។

ផ្អែកតាមស្មារតីអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាសហគមន៍ដែលទទួលលទ្ធផលចាប់ពីមានលក្ខណៈស្តង់ដាឡើងទៅ មានសិទ្ធិទទួលបានការវាយតម្លៃ ដើម្បីទទួលថវិកាគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា។

សាលាមត្តេយ្យសិក្សាសហគមន៍បានបំពេញតាមស្តង់ដាអប្បបរមា គឺជាសូចនាករដ៏សំខាន់មួយក្នុងការវាស់វែងគុណភាពនៃសេវាអប់រំកុមារតូច។ សាលាមត្តេយ្យសិក្សាសហគមន៍បានបំពេញតាមស្តង់ដាអប្បបរមាបានកើនឡើងពី ៦០០ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ១ ៤៣៨ ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ ស្មើ ៤២,៩ ភាគរយ ធៀបទៅនឹងសាលាមត្តេយ្យសិក្សាសហគមន៍ទាំងអស់នៅទូទាំងប្រទេស។

ចាប់ពីឆ្នាំសិក្សា២០១៨-២០១៩ មកក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់ថវិកាគាំទ្រជាបន្តបន្ទាប់ដល់មត្តេយ្យសិក្សាសហគមន៍ដែលជាប់ស្តង់ដាអប្បបរមា សម្រាប់ឧបត្ថម្ភគ្រូ និងគាំទ្រកិច្ចដំណើរការ ដែលគិតជាថវិកាសរុបប្រមាណជិត ១៧ លានដុល្លារអាមេរិក នៅក្នុងរយៈពេល ៧ឆ្នាំកន្លងមកនេះ។

តារាង ១៖ថវិកាក្រសួងសម្រាប់គាំទ្រមត្តេយ្យសិក្សាសហគមន៍ស្តង់ដាចាប់ពីឆ្នាំ២០១៨

ល.រ	ឆ្នាំអនុវត្ត	ច្បាប់ហិរញ្ញវត្ថុ	ចំនួន	អនុវត្តជាក់ស្តែង		
				ឯកតា	ចំណាយឯកតា	សរុបចំណាយ
1	2	3	4	5	6	7
១	២០១៨	4,620,000,000	600	ថ្នាក់	7,700,000	4,620,000,000
២	២០១៩	7,055,000,000	850	ថ្នាក់	8,300,000	7,055,000,000
៣	២០២០	8,967,000,000	1050	ថ្នាក់	8,540,000	8,967,000,000
៤	២០២១	10,675,000,000	1250	ថ្នាក់	8,540,000	10,675,000,000
៥	២០២២	10,675,000,000	1250	ថ្នាក់	8,540,000	10,675,000,000
៦	២០២៣	11,771,100,000	1305	ថ្នាក់	9,020,000	11,771,100,000
៧	២០២៤	14,006,120,000	1438	ថ្នាក់	9,740,000	14,006,120,000
សរុបរួម		67,769,220,000	1438	ថ្នាក់		67,769,220,000

ប្រភព ៖ នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ ២០២៤

ខ. កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ត្រូវបានអ្នកពាក់ព័ន្ធសំខាន់ៗ ចាត់ទុកជាមហិច្ឆតាដែលគ្របដណ្តប់លើដំណោះស្រាយនៃបញ្ហាជាច្រើន សំដៅប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍ចំនួនជាង ៣ ០០០កន្លែង ដែលជាទូទៅរៀបចំបង្កើត និងគាំទ្រដោយដៃគូអភិវឌ្ឍ និងសហគមន៍ អាចបន្តពង្រីកការផ្តល់សេវាអប់រំកុមារតូចប្រកបដោយគុណភាព និងនិរន្តរភាព។ ការពង្រីក និងលើកកម្ពស់គុណភាពសេវាមត្តេយ្យសិក្សាសហគមន៍ ជាជម្រើសដែលប្រសើរបំផុតក្នុងការឆ្លើយតបកម្មវិធីកំណែទម្រង់ស៊ីជម្រៅវិស័យអប់រំ ដោយផ្តើមចេញពីការពង្រីកសេវានិងលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។ ការស្ថាបនាមូលដ្ឋានគ្រឹះសម្រាប់កុមារតូចកាន់តែរឹងមាំ តាមរយៈការផ្តល់ឱកាសឱ្យកុមារដែលមានអាយុចាប់ពី ០៣ឆ្នាំ ដល់ក្រោម ០៦ឆ្នាំ ទាំងអស់ទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ជួយឱ្យពួកគេត្រៀមខ្លួនជាស្រេច ក្នុងការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាឱ្យបានត្រឹមត្រូវតាមអាយុរបស់ខ្លួន កាត់បន្ថយអត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា ជួយដល់ការលើក

កម្ពស់លទ្ធផលសិក្សាសិស្សគ្រប់ភូមិសិក្សានិងជាមូលដ្ឋានសម្រាប់ការសិក្សាពេញមួយជីវិត។ កត្តាទាំងនេះនាំទៅដល់ការបង្កើនចំនួនយុវជននិងមនុស្សពេញវ័យដែលមានចំណេះដឹងផ្នែកអក្ខរកម្ម លេខនព្វន្ត និងជំនាញទន់ រួមជាមួយជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីទទួលបានការងារ និងសហគ្រិនភាព ឆ្លើយតបនឹងគោលដៅនៃការអប់រំ២០៣០ និងតម្រូវការមូលធនមនុស្សសម្រាប់ចក្ខុវិស័យអភិវឌ្ឍកម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ និងឆ្នាំ២០៥០។

ការសិក្សាស្រាវជ្រាវនិក្ខេបបទថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ស្តីពី «កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា» ត្រូវបានរៀបចំឡើង។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ៖

1. សិក្សាស្វែងយល់ពីក្របខណ្ឌទស្សនាទាន នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។
2. សិក្សាពីស្ថានភាពបច្ចុប្បន្ននិងការចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។
3. សិក្សាស្វែងយល់ពីតម្រូវការអាទិភាព នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។
4. អភិវឌ្ឍយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

ខ.១. ក្របខណ្ឌទស្សនាទានៃការស្រាវជ្រាវ

ខ.១.១. ក្របខណ្ឌទស្សនាទានៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

ក្របខណ្ឌគំនិត នៃយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដែលនាំមកនូវការកែលម្អគុណភាពនៃសេវាគាំពារនិងអប់រំកុមារតូចនៅកម្ពុជា ដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគំនិតចម្រុះថ្មីមួយ ដែលមាន៤សមាសភាគ គឺ ៖ ១.ស្វ័យភាព ២.ការវាយតម្លៃ ៣.គណនេយ្យភាព និង៤.ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន (UNESCO, 1989; Anson, 1994; Fullan, 2007; Bruns et al., 2011; Elmore, 2004; P. Glewwe, 2014; Patrinos, Velez & Wang, 2013; Hoy& Miskel, 2008; MoEYS, 2017; WB, 2018) ។

១. ស្វ័យភាព (Autonomy)៖

កំណែទម្រង់សាលាមត្តេយ្យសិក្សាសហគមន៍អាចអនុវត្តទៅតាមគោលការណ៍ស្វ័យភាព នៃការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព(SBM)តាមរយៈ៖

a. ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន៖ សមាសភាគមួយដ៏សំខាន់មិនអាចខ្វះបានក្នុងការពង្រឹងការគ្រប់គ្រងសាលារៀនប្រកបដោយប្រកបដោយប្រសិទ្ធភាព គឺការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដោយមានការចូលរួមពីមាតាបិតានិងអាជ្ញាធរមូលដ្ឋាន គោលដៅនៃការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនគឺដើម្បីពិភាក្សារួមគ្នារវាងគណៈគ្រប់គ្រងសាលារៀន ជាមួយនឹងមាតាបិតានិងអាជ្ញាធរមូលដ្ឋានក្នុងការធានាឱ្យសាលារៀនបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយជោគជ័យ។ ភារកិច្ចដ៏សំខាន់នៃគណៈកម្មការគ្រប់គ្រងសាលារៀនគឺការសិក្សាពីតម្រូវការសាលារៀននិងការដាក់ចេញនូវវិធានការ ដើម្បីបំពេញតាមតម្រូវការរបស់សាលារៀន (Bruns et al., 2011; Elmore, 2014; MoEYS, 2017; Gelsthorpe et al., 2003; Patrinos, et al., 2013; Fullan,2007; Hawley, 2007; ហង់ជួន, ២០២០)។ Daft and Becker (1978) ដែលបានលើកឡើងដោយFullan (2007) បានរកឃើញថាក្រុមសហគមន៍ដែលមានការអប់រំកាន់តែខ្ពស់ ជាទូទៅបានជាក់សម្តែងលើសាលារៀនរបស់ពួកគេឱ្យងាកទៅរកគុណភាពខ្ពស់ ការផ្លាស់ប្តូរលើផ្នែកសិក្សាខណៈដែលសហគមន៍មានការអប់រំតិចតួចមិនទំនងជាចង់ឱ្យផ្លាស់ប្តូរទេ ឬជាក់សម្តែងលើអ្នកអប់រំ ដើម្បីផ្តួចផ្តើមការផ្លាស់ប្តូរ។ Fullan (2007) បានសន្និដ្ឋានថាឪពុកម្តាយនិងសហគមន៍ ដែលមានការអប់រំតិចតួច មិនមានទំនុកចិត្តអំពីបញ្ហាបច្ចេកទេសហើយស្ទើរតែមិនមានទំនាក់ទំនងជាមួយសាលារៀន។

b. ការកៀរគរធនធានតាមរយៈការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន៖ ការចូលរួមរបស់ឪពុកម្តាយសិស្សនិងសហគមន៍នៅក្នុងកំណែទម្រង់សាលារៀន ត្រូវបានគេកំណត់ថាជាគន្លឹះនៃភាពជោគជ័យនៃកម្មវិធីកំណែទម្រង់ និងជាការចាំបាច់ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈឧបទេសដែលក្នុងការលើកកម្ពស់គុណភាព អប់រំកុមារតូច និងការចូលរួមក្នុងដំណើរការសម្រេចចិត្តក្នុងការគ្រប់គ្រងសាលារៀន។ ការផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ជួយលើកកម្ពស់ការផ្តល់សេវាការបណ្តុះបណ្តាលគ្រូការអភិវឌ្ឍនិងការជួសជុលហេដ្ឋារចនាសម្ព័ន្ធ។ សារៈប្រយោជន៍នៃការចូលរួមរបស់សហគមន៍គឺបង្កើនការទុកចិត្តគ្នារវាងសហគមន៍គ្រូបង្រៀន និង សាលារៀន។ ការទុកចិត្តនេះអាចកសាង និងកែលម្អការចូលរួម និងការបរិច្ចាករបស់សហគមន៍ជួយដល់សាលារៀន។ សាលារៀននិងគ្រូបង្រៀនត្រូវឆ្លើយតបទៅនឹងតម្រូវរបស់សហគមន៍ និងមាតាបិតាតាមគោលការណ៍គណនេយ្យភាព នេះមានន័យថាគ្រប់ធនធានដែលសាលារៀនបានទទួលពីរដ្ឋាភិបាល ដៃគូ អភិវឌ្ឍវិស័យឯកជន និងសហគមន៍ត្រូវបានប្រើប្រាស់ក្នុងការអនុវត្តអាទិភាពដែលបានរកឃើញពេលកសាងផែនការ និងគ្រោងថវិកា។ (Fullan, 2007; Bruns et al., 2011; Gelsthorpe et al., 2003; Patrinos, et al., 2013; Hawley, 2007; MoEYS, 2017; ហង់ជួន, ២០២០) ។

c. ភាពជាអ្នកដឹកនាំរបស់នាយកសាលា៖ កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ អាចសម្រេចបានតាម គោលដៅទាល់តែ នាយកសាលាត្រូវមានការប្តេជ្ញាចិត្តខ្ពស់ និងគ្រប់គ្រង

ប្រកបដោយការទទួលខុសត្រូវខ្ពស់ តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំ (Bruns et al., 2011; Fullan, 2014; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០) ។ កំណែទម្រង់ការគ្រប់គ្រងសាលារៀនប្រកបដោយការទទួលខុសត្រូវកម្រិតខ្ពស់ និងភាពជាម្ចាស់របស់គ្រឹះស្ថានសិក្សា ការធានាភាពស័ក្តិសិទ្ធិរបស់អ្នកដឹកនាំនិងការគ្រប់គ្រងតាមសាលារៀន ដើម្បីបង្កើនការគៀរគរធនធាននិងការចូលរួមពីស្ថាប័ននិង វិស័យពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍ ជាពិសេសសហគមន៍ អាណាព្យាបាល និងគ្រូបង្រៀន។

ភាពជាអ្នកដឹកនាំ គឺជាការលើកទឹកចិត្តនិងបង្ហាញពីការយកចិត្តទុកដាក់ដល់ផលប្រយោជន៍រួមជួយអ្នកនៅក្រោមបង្គាប់ឱ្យសម្រេចបានតាមគោលដៅដ៏ខ្ពស់ដោយផ្តោតលើ៖ ១.ការពង្រឹងជំនឿជឿជាក់និងការគោរពពីថ្នាក់ក្រោម ការគិតគូរពីផលប្រយោជន៍រួម ប្រើប្រាស់អំណាចខ្លួនក្នុងគោលដៅបំពេញតាមបេសកកម្ម ទស្សន:វិស័យ ដើម្បីឱ្យថ្នាក់ក្រោមទទួលយកការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងការងាររបស់អង្គភាព ២.ការលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរគំនិតរបស់ថ្នាក់ក្រោមនិងការដោះស្រាយបញ្ហាប្រឈមរបស់អង្គភាពដឹកនាំការបំពេញការងារតាមគោលដៅដែលបានដាក់ចេញហើយផ្សព្វផ្សាយដល់ថ្នាក់ក្រោមឱ្យមានជំនឿជឿជាក់ពីសមត្ថភាពអនុវត្ត និងមានសុទិដ្ឋិនិយម ៣.នវានុវត្តន៍ខាងផ្នែកបញ្ញា (Intellectual stimulation)៖ អ្នកដឹកនាំជំរុញចិត្តថ្នាក់ក្រោមឱ្យមាននវានុវត្តន៍ នឹងមានភាពច្នៃប្រឌិតដោយចេះពិចារណាដោះស្រាយបញ្ហាដោយប្រើវិធីសាស្ត្រថ្មីៗ ៤.យកចិត្តទុកដាក់បុគ្គលម្នាក់ៗ (Individualized consideration)៖ អ្នកដឹកនាំត្រូវយកចិត្តទុកដាក់ដល់តម្រូវការរបស់បុគ្គលិកអ្នក ដើម្បីសម្រេចបាននូវសមិទ្ធផលនិងការអភិវឌ្ឍខ្លួន(Bass and Riggio, 2006)។

២. រង្វាយតម្លៃសិក្សា(Assessment)៖

ជាធម្មតាគ្រូប្រើប្រាស់រង្វាយតម្លៃដើម្បីបែកចែកសិស្សតាមកម្រិតចំណេះដឹង ពិនិត្យមើលបញ្ហារៀនសូត្រ និងវាយតម្លៃជារួមពីភាពជោគជ័យរបស់សាលារៀន (Carnoy and Loeb, 2002) ក៏ប៉ុន្តែគេនៅមិនទាន់អាចបង្កើតទំនាក់ទំនងរវាងគណនេយ្យភាព និងតេស្តបានឡើយ។ ក្នុងន័យនេះនៅក្នុងក្របខណ្ឌនៃចលនាគណនេយ្យភាពបែបថ្មី គោលដៅសំខាន់នៃការធ្វើតេស្តគឺដើម្បីត្រួតពិនិត្យនិន្នាការ កែលម្អនិងពិនិត្យមើលថាតើអន្តរាគមន៍ដូចជាការប្រើប្រាស់ស្តង់ដាថ្មី កម្មវិធីសិក្សានិងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈមានឥទ្ធិពលកម្រិតណាទៅលើលទ្ធផលសិក្សារបស់សិស្ស (Barton, 2001)។

កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍មានគោលដៅពង្រឹងគុណភាពនៃការផ្តល់សេវាអប់រំកុមារតូច ដើម្បីសម្រេចបាននូវលទ្ធផលគ្រប់ជ្រុងជ្រោយ គ្រប់វិស័យនៃការអភិវឌ្ឍ (Heckman, 2006)។ កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ត្រូវផ្សារភ្ជាប់ជាមួយនឹងគោលដៅនៃការពង្រឹងគុណភាពដែលមានរង្វាយតម្លៃសិក្សាជាសមាសភាពមួយយ៉ាងសំខាន់(Bruns et al., 2011; Gelsthorpe et al., 2003; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០) ។ រង្វាយតម្លៃសិក្សានៃការអប់រំកុមារតូច ត្រូវផ្តោតទៅលើ៖

a.ការកែលម្អកម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ៖ កម្មវិធីសិក្សាមានតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពនៃការអប់រំ និងគាំពារកុមារតូច ដែលជួយដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងត្រៀមកុមារសម្រាប់ការចូលរៀនក្នុងសាលា (Yoshikawa et al., 2013; Elmore, 2014; Hawley, 2007; Taguma et al., 2012; ហង់ជួន, ២០២០) ។ កម្មវិធីសិក្សាត្រូវមានគោលដៅសម្រេចបាន ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ ដូចជាការអភិវឌ្ឍរាងកាយ ការអភិវឌ្ឍពុទ្ធិបញ្ញា ការអភិវឌ្ឍសង្គម ការអភិវឌ្ឍផ្លូវអារម្មណ៍ (Emotional)ជាដើម។

b. ការកែលម្អវិធីសាស្ត្ររៀន និងបង្រៀន៖ កម្មវិធីសិក្សាដែលទទួលបានជោគជ័យត្រូវផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលគ្រូ និងការអនុវត្តគរុកោសល្យ ជាពិសេសត្រូវមានគ្រូដែលមានបទពិសោធជួយផ្តល់ប្រឹក្សា និងគាំទ្រនៅក្នុងបន្ទប់រៀន (Bruns et al., 2011; Elmore, 2014; Gelsthorpe et al., 2003; Fullan, 2007; Hawley, 2007; MoEYS, 2017; ហង់ជួន, ២០២០) កម្មវិធីសិក្សាទៅផ្តោតលើរង្វាយតម្លៃតាមដំណាក់កាលផងដែរ ដើម្បីជួយគ្រូត្រួតពិនិត្យវឌ្ឍនភាពរបស់កុមារ និងជួយបង្រៀនកុមារម្នាក់ៗទៅតាមតម្រូវការផ្ទាល់ខ្លួន ។ ក្របខណ្ឌកម្មវិធីសិក្សា និងវិធីសាស្ត្រគរុកោសល្យ ត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ដូចជាការបង្កើតតម្លៃកិច្ចសហការ ជំនឿទុកចិត្ត ស្វ័យភាព ការរៀនតាមបែបសកម្ម និងសុខុមាលភាពរបស់កុមារ។ ដើម្បីអនុវត្តកម្មវិធីសិក្សា និងគរុកោសល្យ ត្រូវមានកម្មវិធីបណ្តុះបណ្តាលគ្រូ ដោយកំណត់ចំនួនម៉ោងសិក្សាតាមមេរៀននីមួយៗ ការចូលរួមរបស់គ្រួសារការលេងល្បែងសិក្សា អន្តរកម្មរវាងគ្រូនិងសិស្ស ការគាំទ្រខាងផ្នែកសុខភាព និងអាហារូបត្ថម្ភ ។ គ្រូត្រូវផ្តល់ឱកាសឱ្យក្មេងមានបទពិសោធច្រើន ដើម្បីពង្រឹងមូលដ្ឋានគ្រឹះសម្រាប់យល់ពីទស្សនទានថ្មីៗ និងរៀនភាសា ដូចជានាំកុមារទៅមើលសួនសត្វ ចូលបណ្ណាគារ ស្តាប់រឿងនិទាន ស្តាប់ភ្លេង និងបង្រៀនកុមារឱ្យចេះរៀបរាប់រាប់ពីសកម្មភាពដែលគេបានធ្វើ បានស្តាប់ បានឃើញ បានភ្លក់រសជាតិជាដើម (UNICEF, 2020; Patrinos, et al., 2013)។

c.ការផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សដល់ភាគីពាក់ព័ន្ធ៖ ការរៀបចំផែនការកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ត្រូវចាប់ផ្តើមពីការពិនិត្យមើលលទ្ធផល នៃរង្វាយតម្លៃតាមកម្រិតថ្នាក់ តាមមុខវិជ្ជា និងតាមក្រុមកុមារតូចដោយគ្រូប្រចាំថ្នាក់ (Formative assessment) ហើយតាមរយៈទិន្នន័យទាំងនេះគេអាចកំណត់ ពីកម្រិតអភិវឌ្ឍរបស់សិស្ស។ នាយកត្រូវយកលទ្ធផលសិក្សារបស់កុមារទៅពិភាក្សាជាមួយគ្រូបង្រៀន ដើម្បីកែលម្អវិធីសាស្ត្រគរុកោសល្យ កែលម្អកិច្ចតែងការបង្រៀន។ នាយកត្រូវជួបពិភាក្សាជាមួយមាតាបិតា ដើម្បីស្វែងយល់ពីការរំពឹងទុកពីលទ្ធផលសិក្សារបស់សិស្សផងដែរ ជាពិសេសដើម្បីផ្តល់ព័ត៌មានទាក់ទងនឹងការគាំពារ និងកម្មវិធីអប់រំមាតាបិតា និងបង្កើតបរិស្ថានវិជ្ជមាននៅផ្ទះ ដែលគាំទ្រដល់ការអភិវឌ្ឍរបស់កុមារ ជាពិសេសការបង្រៀនកុមាររលេងល្បែងសិក្សា ការនិទានរឿង ការច្រៀងចម្រៀង អំណានជាដើម (Elmore, 2004; Fullan, 2014; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០; UNICEF, 2020) ។

ជារួមរង្វាយតម្លៃការសិក្សាត្រូវមានសមាសភាគដូចតទៅ ៖ a.ការកែលម្អកម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ b.ការកែលម្អវិធីសាស្ត្ររៀន និងបង្រៀន និងc.ការផ្សព្វផ្សាយជាសាធារណៈលទ្ធផលសិក្សារបស់សិស្សដល់ភាគីពាក់ព័ន្ធ ។

៣. គណនេយ្យភាព(Accountability)

កំណែទម្រង់សាលារៀនក្នុងប្រទេសជាច្រើនមាននិន្នាការរួម ដើម្បីបង្កើតគណនេយ្យភាព និងការផ្ទេរការទទួលខុសត្រូវពីថ្នាក់ជាតិទៅថ្នាក់មូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មាតាបិតានិងការកែលម្អគុណភាពអប់រំ (Bruns et al., 2011; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០)។ ការបង្កើតគណនេយ្យភាពក្នុងការគ្រប់គ្រងសាលាមត្តេយ្យ សិក្សាសហគមន៍ គឺជាវិធីសាស្ត្រអនុវត្តវិមជ្ឈការនៃការអប់រំដើម្បីឱ្យសេវាអប់រំមានប្រសិទ្ធភាព។ ការសិក្សាបង្ហាញថា មាតាបិតា និងសហគមន៍អាចជាក់សម្ពាធលើសាលាឱ្យកែលម្អសមិទ្ធផលសាលារៀន និងកែលម្អលទ្ធផលសិក្សារបស់សិស្ស មាតាបិតា អ្នកពាក់ព័ន្ធអាចប្រើប្រាស់ព័ត៌មាន ដើម្បីចូលរួមក្នុងការគ្រប់គ្រងសាលានិងត្រួតពិនិត្យសមិទ្ធផលសាលារៀន (Bruns et al., 2011; Fullan, 2007)។ ការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ច និងការបង្កើតប្រព័ន្ធគណនេយ្យភាពក្នុងសាលារៀនតាមរយៈ៖

a. ការបង្កើតផែនការកែលម្អសាលារៀន៖ សាលាល្អត្រូវមានផែនការអភិវឌ្ឍដែលរៀបចំឡើងដោយមានការចូលរួមពីគណៈគ្រប់គ្រង គ្រូបង្រៀន មាតាបិតា សហគមន៍ក្រុមប្រឹក្សាយុវជន និងអាជ្ញាធរដែលពាក់ព័ន្ធក្នុងគោលដៅដោះស្រាយបញ្ហាប្រឈមចំពោះមុខ និងគាំទ្រដោយធនធានថវិកាគ្រប់គ្រាន់ (ហង់ជួន,២០២០; Bruns et al., 2011; Elmore, 2014; Gelsthorpe et al., 2003; Hawley, 2007; Fullan, 2007; MoEYS, 2017; Patrinos, et al., 2013) ។ ផែនការនេះត្រូវឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយនិងសមាសភាពផ្សេងៗ បូកសរុបចូលគ្នាតែម្តងហើយបង្កើតជាការផ្តល់សេវាគាំពារ និងអប់រំកុមារតូចដែលប្រទាក់ក្រឡា។ សេវាប្រទាក់ក្រឡា(Integrated services) ជួយគាំទ្រឱ្យកុមារតូចទទួលបានផលប្រយោជន៍ និងគាំទ្រដល់ការពង្រឹងគុណភាពនៃការផ្តល់សេវា ជានាបរិស្ថានសិក្សាមានស្ថិរភាពនិងជួយដល់កុមារឆ្លងពីមត្តេយ្យសិក្សាទៅបឋមសិក្សា (Erickson et al., 2015) ។

គណៈគ្រប់គ្រងសាលាជួបជាមួយមាតាបិតានិងអាជ្ញាធរមូលដ្ឋាននៅក្នុងការរៀបចំអនុម័ត និងអនុវត្តផែនការអភិវឌ្ឍសាលារៀនដោយផ្ទាល់។ ដើម្បីឱ្យមានការផ្លាស់ប្តូរនូវវប្បធម៌ និងបរិយាកាសនៅក្នុងសាលារៀនដើម្បីកែប្រែឥរិយាបថរបស់មាតាបិតានិងពង្រឹងទំនាក់ទំនងជាមួយមាតាបិតាឱ្យកាន់តែល្អ។គ្រូក៏ត្រូវប្រែប្រួលឥរិយាបថហើយត្រូវយល់ពីតួនាទីនិងភារកិច្ចរបស់ខ្លួន(Bruns et al., 2011; Elmore, 2014; Fullan, 2007; Glewwe, 2014; MoEYS, 2017) ។

b. គណនេយ្យភាពរបស់នាយក៖ នាយកសាលាមានគណនេយ្យភាពចំពោះអាជ្ញាធរ និងមាតាបិតាក្នុងការប្រើប្រាស់ធនធាន ការប្រើប្រាស់ថវិកាមានគណនេយ្យភាព ជួយកែលម្អគុណភាពបរិស្ថានសិក្សាដែលជាកត្តាសំខាន់បំផុតក្នុងការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ(Evans, 2006)

ដោយជួយបំពេញតម្រូវការរបស់កុមារនិងជួយលើកកម្ពស់ទំនាក់ទំនងគ្រូនិងសិស្ស និងសកម្មភាពល្បែងសិក្សាផងដែរ។ ការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយគណនេយ្យភាព ជួយលើកកម្ពស់ការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈគ្រូ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធ(OECD, 2001; Elmore, 2014; Fullan, 2007; Gelsthorpe et al., 2003; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០)

គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវប្រើប្រាស់ថវិកាដើម្បីអនុវត្តកម្មវិធីដែលបម្រើស្តង់ដាប្រសិទ្ធភាពសាលារៀនដោយផ្តោតលើការងាររៀននិងបង្រៀននិងការផ្តល់សម្ភារៈបង្រៀននិងការកែលម្អវិធីសាស្ត្រគរុកោសល្យការផ្តល់សេវាជួយសិស្សការអភិវឌ្ឍវិជ្ជាជីវៈគ្រូ ការកែលម្អបរិស្ថានថ្នាក់រៀននិងសាលារៀន។តាមរយៈការកែលម្អគុណភាពអប់រំកុមារតូច នាយកសាលាជួយគ្រូឱ្យមានកិត្តិយសនាំឱ្យគ្រូមានការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន ដោយខិតខំប្រឹងប្រែងបង្រៀនកុមារឱ្យចេះតាមកម្មវិធីសិក្សា (ហង់ជួន, 2020)។

c. ការកែលំអបរិស្ថានសិក្សា ដើម្បីកែលម្អលទ្ធផលសិក្សាសិស្ស៖ បរិស្ថានសិក្សាគឺជាកត្តាសំខាន់បំផុតក្នុងការលើកកម្ពស់គុណភាពអប់រំកុមារតូចនិងការអភិវឌ្ឍកុមារជាពិសេសការលើកកម្ពស់អន្តរកម្មរវាងគ្រូនិងសិស្ស និងរវាងសិស្សគ្នាឯង (Bruns et al., 2011; Elmore, 2014; Evans, 2006; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន,២០២០) ។

ការរាស់វែងគុណភាពគាំពារ និងអប់រំកុមារតូច៖ គេមានវិធីសាស្ត្រផ្សេងៗក្នុងការវាស់វែងគុណភាពទៅតាមអាយុកុមារ ប្រភេទនៃការគាំពារ និងសមាសភាពនៃគុណភាព ។ បរិស្ថាន សិក្សាគឺជាសូចនាករដំណើរការ នៃគុណភាពអប់រំកុមារតូចជាពិសេសបរិស្ថានហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈសិក្សា និងការរៀបចំបន្ទប់រៀន។ ប្រការនេះបានជាទំនាក់ទំនងគណនេយ្យភាពរវាងគណៈគ្រប់គ្រងសាលារៀនជាមួយមាតាបិតា និងរវាងសាលារៀនជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងលើកកម្ពស់ការអភិវឌ្ឍរបស់កុមារតូច។

បរិបទសង្គម៖ ជាបរិបទមួយដែលគ្រូ ក្រុមគ្រួសារ និងសិស្សត្រូវតែពឹងពាក់គ្នាក្នុងការបង្កើតបរិយាកាសរៀនសូត្រដោយមានការសហការគ្នារវាងគ្រូ សិស្សដោយមានការជួយលើកទឹកចិត្តពីក្រុមគ្រួសារ (Columbus, et al., 2021; Durlak, et al., 2011; Johnson, & Johnson, 2005; Johnson, & Johnson, 2008) ។ បរិបទគឺជាកម្លាំងសរុបដែលនៅជុំវិញ និងមានអន្តរកម្មជាមួយគំនិត អារម្មណ៍ និងសកម្មភាពរបស់បុគ្គល ដែលកំណត់ការលូតលាស់ និងការរៀនសូត្រ ទាំងផ្នែកខាងក្នុង និងខាងក្រៅ។ កុមារដែលធំឡើងនៅក្នុងគ្រួសារ និងជាសមាជិកនៃសហគមន៍ ដែលមានជាតិ ភាសា សាសនា និងសេដ្ឋកិច្ចរបស់ខ្លួន។ នៅក្នុងសហគមន៍នោះមានសាលារៀន និងគ្រូ ដែលអនុវត្តកម្មវិធីសិក្សា និងគោលនយោបាយរបស់រដ្ឋាភិបាល (Columbus, et al., 2021) ។

៤.ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន(Attention to Teacher)

ក្របខណ្ឌគុណភាពអប់រំកុមារតូចរបស់គ្រប់ប្រទេសទាំងអស់ ផ្តោតលើកត្តាគ្រូបង្រៀន ជាពិសេសគុណវុឌ្ឍិ ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ និងលក្ខខណ្ឌបំពេញការងារដើម្បីបង្កើតបរិយាកាស

វិជ្ជមាន និងអន្តរសកម្មរវាងគ្រូ និងកុមារតូច ដែលមានតួនាទីសំខាន់បង្កើនកែលម្អគុណភាព។ ការយកចិត្តទុកដាក់លើគ្រូបង្រៀនត្រូវផ្តោតលើ៖

a. ការជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិល្អចូលធ្វើគ្រូ៖ គុណភាពនៃប្រព័ន្ធអប់រំគឺជាគុណភាពនៃគ្រូបង្រៀនហើយប្រព័ន្ធសាលារៀនល្អគឺជាសាលារៀនដែលមានមូលដ្ឋានគ្រឹះចំនួន ៣ នៃប្រព័ន្ធអប់រំ(Bruns et al., 2011; Elmore, 2014; Mourshed et al.,2021; MoEYS, 2017; Patrinos, et al., 2013; WB, 2018; ហង់ជួន, ២០២០)៖ ១.យន្តការមានប្រសិទ្ធភាពក្នុងការជ្រើសរើសគ្រូ ដើម្បីជ្រើសរើសបុគ្គលដែលមានគុណសម្បត្តិសមស្របឱ្យក្លាយជាគ្រូបង្រៀន ២.ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈខ្ពស់ ដែលអាចសម្រេចគោលដៅថាគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលនិងការអភិវឌ្ឍវិជ្ជាជីវៈក្លាយជាគ្រូដែលមានវិជ្ជាជីវៈខ្ពស់ដែលអាចសម្រេចបានលទ្ធផលសិក្សាសិស្សល្អប្រសើរ ៣.ប្រព័ន្ធគាំទ្រមានប្រសិទ្ធភាពដើម្បីធានាថាសិស្សទទួលផលបានពីការបង្រៀនដែលជួយឱ្យពួកគេសម្រេចបានសក្តានុពលខ្ពស់។

b. ការបង្កើនប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភ៖ លក្ខខណ្ឌការងាររបស់គ្រូបង្រៀនដូចជាប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍មិនមែនហិរញ្ញវត្ថុជួយដល់អន្តរសកម្មជាវិជ្ជមានរវាងគ្រូនិងកុមារតូចលើកកម្ពស់ការពេញចិត្តចំពោះការងារកាត់បន្ថយអវត្តមាន និងជួយទាក់ទាញបេក្ខជនដែលមានគុណវុឌ្ឍិខ្ពស់ឱ្យចូលធ្វើគ្រូ។ កត្តាទាំងនេះ និងកែលម្អគុណភាពនៃអន្តរកម្មរវាងគ្រូនិងកុមារតូច(Bruns et al., 2011; Fullan, 2007 ; Taguma et al., 2012; MoEYS, 2017; Patrinos, et al., 2013; UNICEF, 2020; ហង់ជួន, ២០២០) ។

c. ការអប់រំគ្រូបង្រៀនអាចក្លាយជាអ្នកបោះព្រំមានប្រសិទ្ធភាព ៖គ្រូដែលមានការអប់រំតាមវិជ្ជាជីវៈនៃការអប់រំកុមារតូច គឺជាកត្តាចម្បងនៃការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងជួយខ្លាំងជាងគេដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងបំណិនសង្គមរបស់កុមារតូច។ គ្រូបង្រៀនមិនត្រឹមតែមានគុណវុឌ្ឍិខ្ពស់ប៉ុណ្ណោះទេ តែត្រូវមានសមត្ថភាពនៅក្នុងការបង្កើតបរិស្ថានគរុកោសល្យ ដែលមានគុណភាពខ្ពស់ Anson (1994) Bruns et al., (2011); Elmore, (2014); Fullan, (2007); McKinsey and Company (2007); Hanushek and Rivkin (2003); Hawley, (2007); MoEYS, (2017); Patrinos, et al., (2013); ហង់ជួន (២០២០) ។

គរុកោសល្យមានគុណភាពគឺ៖ ១.យល់ពីការអភិវឌ្ឍកុមារតូច ២.អន្តរកម្ម វិជ្ជមានរវាងគ្រូនិងសិស្ស ៣.ភាពជាអ្នកដឹកនាំដោះស្រាយបញ្ហានិងការរៀបចំកិច្ចតែងការ ៤. សមត្ថភាពបង្កើតបរិស្ថានការងារប្រកបដោយប្រសិទ្ធភាព។ ការអភិវឌ្ឍវិជ្ជាជីវៈបន្តជួយគ្រូបង្រៀនឱ្យរៀនសូត្រពីឧត្តមានុវត្តន៍ និងកែលម្អគរុកោសល្យ នឹងជួយជំរុញនូវការអភិវឌ្ឍកុមារ។

តារាងទី ២.៣៖ក្របខណ្ឌទស្សនាទានកំណែទម្រង់ការគ្រប់គ្រងសាលាមតេ្តយ្យសិក្សាសហគមន៍

	UNESCO, 1989	Anson, 1994	Elmore, 2004	Fullan, 2007	Hoy& Miskel, 2008	Bruns et al., 2011	Glewwe, 2014	MoEYS, 2017	WB, 2018
1. ស្វ័យភាព									
1.1. ភាពជាម្ចាស់ និងគណៈកម្មការគ្រប់គ្រងសាលារៀន	✓		✓	✓	✓			✓	✓
1.2. ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន	✓			✓	✓	✓		✓	
1.3. ភាពជាអ្នកដឹកនាំរបស់នាយក	✓	✓		✓		✓	✓	✓	
2. រង្វាយតម្លៃសិក្សា									
2.1. កម្មវិធីសិក្សា និងសៀវភៅគ្រូ			✓	✓				✓	✓
2.2. វិធីសាស្ត្ររៀន និងបង្រៀន	✓	✓	✓	✓				✓	✓
2.3. ការផ្សព្វផ្សាយលទ្ធផលសិក្សា				✓	✓			✓	✓
3. គណនេយ្យភាព									
3.1. ផែនការកែលម្អសាលារៀន	✓							✓	✓
3.2. គណនេយ្យភាពរបស់នាយក	✓		✓		✓	✓		✓	✓
3.3. ការកែលម្អបរិស្ថានសិក្សា								✓	✓
4. យកចិត្តទុកដាក់ដល់គ្រូបង្រៀន									
4.1. បេក្ខជនមានលក្ខណៈសម្បត្តិល្អ	✓		✓			✓	✓	✓	✓
4.2. ប្រាក់បៀវត្ស ការលើកទឹកចិត្ត			✓	✓		✓	✓	✓	✓
4.3. ការបណ្តុះបណ្តាលគ្រូ		✓		✓		✓	✓	✓	✓

នៅក្នុងដំណើរការនៃការធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ឈរលើមូលដ្ឋាននៃក្របខណ្ឌទស្សនាទានចម្រុះថ្មីខាងលើ សំដៅកែលម្អលទ្ធផលសិក្សា និងគុណភាពនៃការអប់រំកុមារតូច ជាពិសេសការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ ធានាឱ្យកុមារតូចគ្រប់រូបមានការអភិវឌ្ឍសមាសភាគទាំង៣ របស់កុមារ ដែលផ្តល់លទ្ធភាពឱ្យកុមារទទួលបានពេញលេញនូវសុខុមាលភាពរាងកាយ ផ្លូវចិត្ត ស្មារតី សាមគ្គីភាព ភាពម្ចាស់ការ ការទទួលខុសត្រូវ សមត្ថភាពពិចារណា ការដោះស្រាយបញ្ហា បំណិនអន្តរកម្មបុគ្គលនិងសង្គម ស្មារតីស្រឡាញ់បរិស្ថាន និងការចូលចិត្តរបស់កុមារ ជាមូលដ្ឋានគ្រឹះឱ្យពួកគេក្លាយជាពលរដ្ឋពេញលេញ និងជាពលរដ្ឋសកលប្រកបដោយការទទួលខុសត្រូវនាពេលអនាគត (Hanushek & Woessman, 2008 Heckman, 2000; PIAGET, 1963; VYGOTSKY, 1987a; UNICEF, 2020; Whitebreat et al., 2015; Woolfolk, 2016) ។

ខ.១.២. ក្របខណ្ឌទស្សនាទាននៃគុណភាពអប់រំកុមារតូចនៅកម្ពុជា

បញ្ញត្តិនៃគុណភាពនៃការអប់រំកុមារតូច ជាទំនាក់ទំនងទៅវិញទៅមករវាងបំណិនចិត្តចលករ បំណិនពុទ្ធិបញ្ញា និងបំណិនមិនមែនពុទ្ធិបញ្ញា (Heckman, 2000; Heckman, Pinto, & Savelyev, 2013; Heckman & Rubinstein, 2001; Woolfolk, 2016)៖

១.ការអភិវឌ្ឍរាងកាយ និងចលករ (Physical and Motor Development)៖ ការអភិវឌ្ឍរបស់មនុស្សបណ្តាលមកពីកត្តាពីរ គឺ៖ ការលូតលាស់ (growth) និងភាពចាស់ទុំ (maturation)។ ការអភិវឌ្ឍរាងកាយគឺជាការលូតលាស់តាមធម្មជាតិ ដោយគ្មានទទួលរងឥទ្ធិពលពីមជ្ឈដ្ឋានឡើយ លើកលែងតែអាហារូបត្ថម្ភ និងជម្ងឺតម្កាត់។ ការស្រាវជ្រាវបញ្ជាក់ថា៖ «កត្តាធម្មជាតិ» (ពូជ) និង«កត្តាថៃទាំ» មានតួនាទីសំខាន់ដូចគ្នាក្នុងការលូតលាស់របស់ មនុស្ស។ ការអភិវឌ្ឍរាងកាយ និងចលករអាចចែកចេញជា៖

a.សារៈសំខាន់នៃអាហារូបត្ថម្ភ និងការគាំពារក្នុងរយៈពេល ១០០០ ថ្ងៃដំបូង (The importance of nutrition and care during the first 1,000 days)៖ ការស្រាវជ្រាវបង្ហាញថា ការគាំពារ និងការអប់រំដែលមានគុណភាពផ្តល់អត្ថប្រយោជន៍ជាវិជ្ជមានយ៉ាងខ្លាំងក្លាដល់កុមារតូច ទាំងនៅក្នុងរយៈពេលខ្លី និងនៅរយៈពេលវែង (UNICEF, 2020)។

ដំណាក់កាល ១០០០ថ្ងៃដំបូងរបស់កុមារដែលមាតាបិតាត្រូវផ្តល់អាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យខួរក្បាលមានការលូតលាស់បានល្អ សំខាន់ណាស់ពីព្រោះក្នុងដំណាក់កាលនេះខួរក្បាលក្មេងមានការលូតលាស់យ៉ាងលឿន។ ការធ្វើអន្តរកម្មជាមួយមនុស្ស និងបរិស្ថាន គឺជាតម្រូវការសម្រាប់ការអភិវឌ្ឍយ៉ាងលឿននៃខួរក្បាលកុមារតូច។ ខួរក្បាលរបស់កុមារអាយុ ៣ ឆ្នាំអាចអភិវឌ្ឍរហូតដល់ទៅ ៨០%នៃខួរមនុស្សធំ និងដល់ ៩០% នៅអាយុ ៥ ឆ្នាំ។ នៅក្នុងដំណាក់កាលដែលមានការអភិវឌ្ឍយ៉ាងលឿននេះ ខួរក្បាលមានវេយិតភាពយ៉ាងខ្លាំង ជាមួយបរិស្ថាន ដែលអាចជាឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន។

ការអភិវឌ្ឍនៅដំណាក់កាលដំបូង គឺជាកត្តាកំណត់សម្រាប់ការអភិវឌ្ឍពុទ្ធិបញ្ញា និងការបណ្តុះបំណិនសង្គម ភាពក្លាហាន បំណិនទំនាក់ទំនងជាដើម ដែលសំខាន់សម្រាប់ការធានាជោគជ័យក្នុងជីវិតរបស់កុមារ។ ប្រការនេះមានន័យថា ការគាំពារ និងការអប់រំកុមារតូចត្រូវតែមានគុណភាព និងត្រូវតែមានស្តង់ដាអប្បបរមា ដែលរដ្ឋត្រូវកំណត់ (Woolfolk, 2016)។ ការអភិវឌ្ឍរាងកាយចែកចេញជា ១.ការអភិវឌ្ឍបំណិនចលករកម្លាំង និង ២.ការអភិវឌ្ឍបំណិនចលករបិនប្រសប់។

b.បំណិនចលករកម្លាំង (Gross-motor skills)៖ ការអភិវឌ្ឍរាងកាយរបស់កុមារមិនដូចគ្នាទេ។ ការអប់រំកុមារតូចត្រូវផ្តល់ឱកាសដើម្បីឱ្យកុមារបានលេងច្រើនដើម្បីជំរុញការអភិវឌ្ឍបំណិនចលករកម្លាំង។ នៅអាយុ ១ឆ្នាំ កុមារចាប់ផ្តើម ចេះក្រឡាប់ បន្ទាប់មកវារ និងប្រឹងតោងដើម្បីរៀនដើរឈរ។ នៅពេលអាយុ ២ឆ្នាំក្មេងប្រុសចេះដើរ និងរៀនដើរមុនក្មេងស្រី ដោយសារក្មេងប្រុសមានការលូតលាស់សាច់ដុំលឿនជាងក្មេងស្រី។ នៅអាយុ ៣ឆ្នាំកុមារចាប់ផ្តើមចេះរត់ និង លោត។ ក៏ប៉ុន្តែ ចលនាទាំងនេះនៅមានលក្ខណៈឆ្គាំឆ្គង មិនទាន់ស្ទាត់ ដោយកុមារនៅមិនទាន់ចេះសម្របសម្រួលចលនា (Woolfolk, 2016)។

c.បំណិនចលករបិនប្រសប់ (Fine-motor skills)៖ នៅពេលកុមារចេះសម្របសម្រួលចលនាគឺជាដំណាក់កាលអភិវឌ្ឍបំណិនចលករបិនប្រសប់។ នៅអាយុ ៤ឆ្នាំ កុមារចាប់ផ្តើមរៀនបិទឡេវអាវ ឬចងខ្សែស្បែកជើងដោយខ្លួនឯង។ គ្រូ និងមាតាបិតាត្រូវបង្រៀនឱ្យកុមាររៀនធ្វើសកម្មភាពដោយខ្លួនឯង ដូចជាបង្រៀនកូនឱ្យចេះកាន់ខ្មៅដៃពណ៌ ដើម្បីរៀនគូរ ឬឱ្យចេះកាន់ខ្មៅដៃ និងកាន់ក្រដាសដើម្បីរៀនសរសេរ ដើម្បីឱ្យលូតលាស់បំណិនចលករបិនប្រសប់នេះ។ ការលេងល្បែងសិក្សា គឺជាវិធីបង្រៀនកុមារឱ្យមានការអភិវឌ្ឍទាំងរាងកាយ ទាំងខួរក្បាល (Woolfolk, 2016) ។

២.ការអភិវឌ្ឍពុទ្ធិបញ្ញា (Cognitive development)៖ការអភិវឌ្ឍពុទ្ធិបញ្ញាប្រែប្រួលយ៉ាងខ្លាំងពីវ័យកុមារ ដល់វ័យចំណាស់។ លោកPIAGETពន្យល់ថាការផ្លាស់ប្តូរនេះបណ្តាលមកពីកត្តា ៤គឺ៖ ១. ភាពចាស់ទុំខាងជីវសាស្ត្រ ២.សកម្មភាព ៣.បទពិសោធសង្គម និង ៤.តុល្យភាព ហើយកត្តាទាំង ៤នេះមានអន្តរសកម្ម ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរនៃគំនិត (Piaget, 1970a)។ ទ្រឹស្តីរបស់ PIAGET បែងចែកការអភិវឌ្ឍពុទ្ធិបញ្ញាជាដំណាក់កាល៖ ១.ដំណាក់កាល«ឥន្ទ្រីយ៍ចលករ» កុមារពីអាយុ ០ ទៅ ២ឆ្នាំ ២. ដំណាក់កាល «បុរេប្រតិបត្តិ» នៅពេលកុមាររៀននៅមត្តេយ្យសិក្សា (អាយុពី ២ ទៅ ៧ឆ្នាំ)។ ការអភិវឌ្ឍពុទ្ធិបញ្ញាអាចចែកចេញជាសមាសភាគ ដែលរួមមាន៖

a. ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម (Language development and Literacy)៖ កត្តាជីវសាស្ត្រ វប្បធម៌ និងបទពិសោធដើរតួនាទីក្នុងការអភិវឌ្ឍភាសា (Woolfolk, 2016) ។ ភាសាដើរតួនាទីសំខាន់បំផុតសម្រាប់ការអភិវឌ្ឍពុទ្ធិបញ្ញា ដោយសារភាសា គឺជាមធ្យោបាយដែលបញ្ជូនគំនិត។ ចំណែកឯ VYGOTSKY យល់ឃើញថាការរៀន និងភាសាមានតួនាទីសំខាន់ខ្លាំង ក្នុងការអភិវឌ្ឍពុទ្ធិបញ្ញា ហើយការគិតអាស្រ័យលើសំដី មធ្យោបាយក្នុងការគិត និងបទពិសោធសង្គមវប្បធម៌របស់កុមារ (Vygotsky,

1987a)។ ដើម្បីរៀនភាសាកុមារត្រូវ៖ ១. ស្វែងយល់ពីបំណងរបស់អ្នកផ្សេង ដើម្បីរៀនពាក្យ ល្បះ និងបញ្ញត្តិនៃភាសា ២.រកឱ្យឃើញលំនាំនៃការប្រើប្រាស់ពាក្យ និងល្បះ ដើម្បីសាងវេយ្យាករណ៍នៃភាសា (Tomasello, 2006)។ កុមារត្រូវចេះគិតក្នុងការផ្គុំផ្នែកផ្សេងៗនៃប្រព័ន្ធភាសានេះ ឱ្យទៅជាល្បះបាន (Waxman & Lidz, 2006)។ កុមារអាយុពី ២ ទៅ ៣ឆ្នាំចេះប្រើពាក្យប្រមាណ ៤៥០ពាក្យតែគេយល់ពាក្យច្រើនជាងនេះ។ នៅពេលមានអាយុ ៦ ឆ្នាំកុមារអាចនិយាយបានប្រមាណជា ២ ៦០០ពាក្យតែគេអាចយល់ដល់ទៅជាង ២០ ០០០ ពាក្យ ។ អ្នកសិក្សាស្រាវជ្រាវខ្លះវាយតម្លៃថាកុមារនៅថ្នាក់ដំបូងៗរៀនចេះពាក្យដល់ទៅ ២០ពាក្យក្នុងមួយថ្ងៃ។ ក៏ប៉ុន្តែកុមារនៅមិនទាន់យល់ពាក្យអរូបីពាក្យប្រៀបធៀប និងពាក្យមានបង្គប់នំយនៅឡើយទេ។ អំណានគឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍបំណិនអក្ខរកម្ម (emergence literacy) (Woolfolk, 2016)

b. បុរេគណិត (numeracy)៖ ។ នៅដំណាក់កាលនេះគ្រូនិងមាតាបិតាត្រូវបង្រៀនកុមារតូចយល់ពីសញ្ញាណបូក និងដកលេខ (បុរេគណិត) តាមរយៈការលេងល្បែងសិក្សា។ (Woolfolk, 2016)

c.បំណិនដោះស្រាយបញ្ហា (Problem solving)៖ ការដោះស្រាយបញ្ហាគឺជាមូលដ្ឋាននៃការរៀនរបស់កុមារតូច។ តាមរយៈការសាកល្បងដោះស្រាយបញ្ហាលេងជាមួយវត្ថុផ្សេងៗ និងទំនាក់ទំនងសង្គម កុមារស្ថាបនាចំណេះដឹង ដោយការសាកល្បង។ PIAGET (1963)កុមារយល់នៅពេលដែលគេស្វែងរកឃើញ និងបង្កើតដោយខ្លួនឯង។ VYGOTSKY ជឿជាក់ថាឧបករណ៍ចិត្តវិទ្យាជួយដល់ការគិតកម្រិតខ្ពស់ ដូចជាការគិតបែបត្រិះរិះ និងការដោះស្រាយបញ្ហា។ គ្រូ និងមាតាបិតាត្រូវបង្កើតឱកាសដើម្បីដោះស្រាយបញ្ហា តាមរយៈការទុកពេលឱ្យកុមារលេង ផ្តល់ទីកន្លែង និងផ្តល់វត្ថុ ដើម្បីឱ្យកុមារលេង។ កម្មវិធីសិក្សាកុមារតូចត្រូវបញ្ចូលការបង្រៀន តាមរយៈការដោះស្រាយបញ្ហា ទៅតាមកម្រិតនៃការអភិវឌ្ឍ និងចំណង់ចំណូលចិត្តផ្សេងគ្នារបស់កុមារ ដើម្បីឱ្យកុមារចេះធ្វើការជ្រើសរើស និងធ្វើការសម្រេចចិត្តដោយខ្លួនឯង (Katz, L. & Chard, S. 1989) ។

៣.ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា (Development of Non-Cognitive Skills)៖ បំណិនមិនមែនពុទ្ធិបញ្ញា ឬបំណិនទន់ (Soft skills) និងបំណិនជីវិត គឺជា៖ a.ការគិតប្រកបដោយការត្រិះរិះពិចារណា និងនវានុវត្តន៍ b.បំណិនអន្តរបុគ្គល (ការប្រាស្រ័យទាក់ទង, ការធ្វើការជាក្រុម ការសហការ ការយល់ចិត្ត អាណិតអាសូរ..) និង c. បំណិនគ្រប់គ្រងខ្លួនឯង(វិន័យផ្ទាល់ខ្លួន សមត្ថភាពក្នុងការរៀនឯករាជ្យ ភាពបត់បែន និងសម្របខ្លួន ការយល់ដឹងពីខ្លួនឯង ការតស៊ូ ការលើកទឹកចិត្តខ្លួនឯង មេត្តាធម៌ សុចរិតភាព ការគោរពខ្លួនឯង) (Hanushek & Woessmann, 2008; Heckman, 2000; UNESCO, 2015)។ បំណិនមិនមែនពុទ្ធិបញ្ញាមានសមាសភាគដូចតទៅ៖

a.បំណិនសង្គម (Social skill)៖ យោងតាមការស្រាវជ្រាវផ្នែកចិត្តវិទ្យា និងបំណិនពុទ្ធិបញ្ញា Heckman (2000) សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការបង្កើតបំណិនសង្គម នៅក្នុងដំណាក់កាលនៃការអប់រំកុមារតូច ដោយក្រុមគ្រួសារ និងបរិស្ថានក្រៅសាលា។ បំណិនសង្គមដែលបង្កើតក្នុងវ័យកុមារតូច

មុនពេលចូលសាលារៀនអាចនាំមកនូវភាពជោគជ័យ ឬបរាជ័យក្នុងសាលារៀន និងបន្ទាប់ពីបញ្ចប់ការសិក្សាក្នុងសាលារៀន។ ភាគច្រើននៃប្រសិទ្ធភាពនៃអន្តរាគមន៍នៅវ័យកុមារអាចរួមចំណែកដល់ការបង្កើតបំណិនពុទ្ធិបញ្ញា និងបង្កើតជាការលើកទឹកចិត្តនៅក្នុងជីវិត (Heckman, 2000)។

b.ស្វ័យគ្រប់គ្រង (Self-management)៖ ដោយផ្អែកលើការសិក្សានាពេលបច្ចុប្បន្នទាក់ទងនឹងការអប់រំនិងបណ្តុះបណ្តាល Heckman (1998)បានលើកឡើងថា មនុស្សដែលមាន IQ ខ្ពស់ទទួលបរាជ័យក្នុងជីវិត ដោយសារពួកគេខ្វះការគោរពខ្លួនឯង ហើយមនុស្សមាន IQ ទាប តែទទួលបានជោគជ័យ ដោយសារពួកគេចេះតស៊ូ និងមានវិន័យផ្ទាល់ខ្លួន ខ្លួន (Heckman & Rubinstein, 2001; Heckman et al. 2013)។ Jencks (1979) រកឃើញថាទម្លាប់បុគ្គលដូចជាភាពជាភាពជាអ្នកដឹកនាំ ឧស្សាហ៍ព្យាយាម និង ការខិតខំជាបន្តបន្ទាប់ មានឥទ្ធិពលទាក់ទងគ្នាទៅលើ ចំណូលរបស់បុគ្គលម្នាក់ៗ ហើយភាពជោគជ័យក្នុងការអប់រំ ផ្អែកទៅលើកចរិតលក្ខណៈរបស់គ្រួសារ និងជំនាញពុទ្ធិបញ្ញានិងមិនមែនពុទ្ធិបញ្ញា (Whitebread, et al., 2015)។

c.បំណិនប្រាស្រ័យទាក់ទង (Communication skill)៖ VYGOTSKY ជឿថាសកម្មភាពរបស់មនុស្សប្រព្រឹត្តិទៅក្នុងបរិបទនៃវប្បធម៌ គេត្រូវសិក្សាសកម្មភាពនេះក្នុងបរិបទវប្បធម៌ផងដែរ។ គំនិតសំខាន់របស់លោក គឺរចនាសម្ព័ន្ធ និងដំណើរការអភិវឌ្ឍពុទ្ធិបញ្ញាផ្សារភ្ជាប់ទៅនឹងអន្តរសកម្មរបស់កុមារជាមួយនឹងអ្នកផ្សេងទៀត។ មុខងារខ្ពស់ៗចាប់ផ្តើមជាទំនាក់ទំនងរវាងបុគ្គលមនុស្ស (Vygotsky, 1978)។ ការអភិវឌ្ឍបំណិនប្រាស្រ័យទាក់ទងរបស់កុមារតូច គឺជាការអភិវឌ្ឍបំណិនយល់ និងសំដែងគំនិតនិងអារម្មណ៍។ការប្រាស្រ័យទាក់ទងចាប់ផ្តើមពីនៅក្នុងផ្ទៃ ហើយបន្តរហូតក្នុងជីវិត ដោយកុមារមើលឃើញស្តាប់ និងបកស្រាយព័ត៌មានពីអ្នកផ្សេង។

តារាង ២.៤ ៖ ក្របខណ្ឌទស្សនាទានគុណភាពនៃការអប់រំកុមារតូច

	Hanushek & Woessman, 2008	Heckman, 2000	PIAGET, 1963, 1970a	VYGOTSKY, 1987a	UNICEF, 2020	Whitebread, et al., 2015	Woolfolk, 2016
១. ការអភិវឌ្ឍរាងកាយ និងចលករ							✓
១.១. អាហារូបត្ថម្ភ និងការគាំពារ ១០០០ថ្ងៃដំបូង	✓	✓			✓		✓
១.២. បំណិនចលករកម្លាំង		✓	✓		✓		✓
១.៣. បំណិនចលករប៉ិនប្រសប់		✓	✓		✓		✓

	Hanushek & Woessman, 2008	Heckman, 2000	PIAGET, 1963, 1970a	VYGOTSKY, 1987a	UNICEF, 2020	Whitebread, et al., 2015	Woolfolk, 2016
២. ការអភិវឌ្ឍពុទ្ធិបញ្ញា		✓			✓	✓	
២.១. ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម		✓	✓	✓			✓
២.២. បុរេគណិត			✓	✓			✓
២.៣. បំណិនដោះស្រាយបញ្ហា	✓		✓	✓		✓	✓
៣. បំណិនមិនមែនពុទ្ធិបញ្ញា	✓	✓			✓	✓	
៣.១. បំណិនសង្គម	✓	✓	✓	✓	✓	✓	✓
៣.២. ស្វ័យគ្រប់គ្រង	✓	✓	✓		✓	✓	✓
៣.៣. បំណិនប្រាស្រ័យទាក់ទង	✓	✓	✓	✓	✓	✓	✓

ទំនាក់ទំនងនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីឈានទៅដល់ការលើកកម្ពស់គុណភាពការអប់រំកុមារតូចនៅកម្ពុជា គឺជាគោលបំណងចម្បងបំផុតនៃការសិក្សាស្រាវជ្រាវនេះ។ ការសិក្សានឹងស្វែងរកជាចាំបាច់នូវលក្ខខណ្ឌក្នុងការធានាគុណភាពសេវាមត្តេយ្យសិក្សាសហគមន៍ស្របតាមស្តង់ដាគុណភាពអប់រំកុមារតូចនៅកម្ពុជា និងស្តង់ដាគុណភាពក្នុងតំបន់ រួមទាំងការស្វែងយល់ពីហេតុនិងផល ដែលនាំឱ្យធានាបាននូវគុណភាពសេវាមត្តេយ្យសិក្សាសហគមន៍ស្របតាមស្តង់ដា ព្រមទាំងឈានទៅដល់ការស្វែងរកនូវអនុសាសន៍មានលក្ខណៈប្រតិបត្តិជាក់ស្តែងសម្រាប់ប្រទេសកម្ពុជា។

រូបភាពទី៨៖ ក្របខណ្ឌទស្សនាទាន នៃការស្រាវជ្រាវ

កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ (UNESCO, 1989; Anson, 1994; Fullan, 2007 ; Bruns et al., 2011; Elmore, 2004 ; P. Glewwe, 2014; Patrinos, Velez & Wang, 2013; Hoy& Miskel, 2008; MoEYS, 2017; WB, 2018)៖

1. **ស្វ័យភាព៖**
   - 1.1. គណៈកម្មការគ្រប់គ្រងសាលារៀន
   - 1.2. ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលា
   - 1.3. ភាពជាអ្នកដឹកនាំរបស់នាយក
2. **រង្វាយតម្លៃសិក្សា៖**
   - 1.4. កម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ
   - 1.5. វិធីសាស្ត្ររៀន និងបង្រៀន
   - 1.6. ការផ្សព្វផ្សាយលទ្ធផលសិក្សា
3. **គណនេយ្យភាព៖**
   - 1.7. ការបង្កើតផែនការកែលម្អសាលារៀន
   - 1.8. គណនេយ្យភាពរបស់នាយក
   - 1.9. ការកែលម្អបរិស្ថានសិក្សា
2. **ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន៖**
   - 2.1. ការជ្រើសរើសបេក្ខជនមានលក្ខណៈសម្បត្តិល្អ
   - 2.2. ប្រាក់បៀវត្ស និងការលើកទឹកចិត្ត
   - 2.3. ការបណ្តុះបណ្តាលគ្រូ

គុណភាពនៃការអប់រំកុមារតូច (Hanushek & Woessman, 2008 Heckman, 2000; PIAGET, 1963; VYGOTSKY, 1987a; UNICEF, 2020; Whitebreat et al., 2015; Woolfolk, 2016)៖

4. **ការអភិវឌ្ឍរាងកាយ និងចលករ៖**
   - 4.1. អាហារូបត្ថម្ភ និងការគាំពារក្នុង រយៈពេល១០០០ថ្ងៃដំបូងនៃកំណើត
   - 4.2. បំណិនចលករកម្លាំង
   - 4.3. បំណិនចលករប៉ិនប្រសប់
5. **ការអភិវឌ្ឍពុទ្ធិបញ្ញា៖**
   - 5.1. ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម
   - 5.2. បុរេគណិត
   - 5.3. បំណិនដោះស្រាយបញ្ហា
6. **ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា៖**
   - 6.1. បំណិនសង្គម
   - 6.2. ស្វ័យគ្រប់គ្រង
   - 6.3. បំណិនប្រាស្រ័យទាក់ទង

ការអភិវឌ្ឍយុទ្ធសាស្ត្រ៖

1. វិភាគពីស្ថានភាពបច្ចុប្បន្ន និងការចង់បានប្រែក្លាយនាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា
2. វិភាគបរិស្ថានផ្ទៃក្នុង និងផ្ទៃក្រៅ នៃសាលាមត្តេយ្យសិក្សាសហគមន៍ ដោយប្រើ សន្ទស្សន៍ PNI និងការវិភាគ SWOT
3. អភិវឌ្ឍសេចក្តីព្រាងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយវិភាគម៉ាទ្រិច TOWS
4. បញ្ជាក់ពីភាពត្រឹមត្រូវនៃយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ពីអ្នកជំនាញនិងអ្នកពាក់ព័ន្ធ និងកែលម្អសេចក្តីព្រាងយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

ខ.២ ស្ថានភាពបច្ចុប្បន្ននិងការចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

កម្រងសំណួរជាទម្រង់ឆ្លើយតបទ្វេដង (ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលចង់បាននាពេលអនាគត នៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា) មានលំដាប់ថ្នាក់ពិន្ទុមធ្យមភាគ (Mean) ៥កម្រិត បានយកទៅប្រមូលទិន្នន័យជាមួយសំណាកចំនួន ៥១៩នាក់ ដើម្បីវិភាគកំណត់ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុកនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពការអប់រំកុមារតូចនៅកម្ពុជា។ តារាងខាងក្រោមនឹងបង្ហាញអំពីស្ថានភាពបច្ចុប្បន្ននិងស្ថានភាពដែលចង់បាននៃសមាសភាគធំៗទាំង០៤របស់ កំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ព្រមទាំងតម្លៃនៃកម្រិត និងលំដាប់លំដោយនៃស្ថានភាពបច្ចុប្បន្ន និងលំដាប់លំដោយនៃស្ថានភាពដែលចង់បាននាពេលអនាគត។

តារាង២៖ ស្ថានភាពបច្ចុប្បន្ននិងស្ថានភាពដែលចង់បាននៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

កំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	**ស្ថានភាពបច្ចុប្បន្ន**				**ស្ថានភាពរំពឹងទុក**			
	M	SD	L	O	M՝	SD՝	L՝	O՝
១. ស្វ័យភាព	3.22	0.63	មធ្យម	4	4.70	0.42	ខ្ពស់	1
២. រង្វាយតម្លៃការសិក្សា	3.42	0.54	មធ្យម	1	4.66	0.43	ខ្ពស់	4
៣. គណនេយ្យភាព	3.24	0.62	មធ្យម	2	4.70	0.40	ខ្ពស់	1
៤. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន	3.24	0.55	មធ្យម	3	4.67	0.41	ខ្ពស់	3
សរុបរួម	**3.28**	**0.53**	**មធ្យម**		**4.69**	**0.39**	**ខ្ពស់**	

ចំណាំ៖ M=មធ្យមភាគបច្ចុប្បន្ន; SD =គម្លាតស្តង់ដាបច្ចុប្បន្ន ; L= កម្រិតបច្ចុប្បន្ន ; O = លំដាប់បច្ចុប្បន្ន; M՝= មធ្យមភាគដែលចង់បាន; SD՝ = គម្លាតស្តង់ដាដែលចង់បាន; L՝ = កម្រិតដែលចង់បាន; O՝ = លំដាប់ដែលចង់បាន

រូបភាពទី៩ ៖ ស្ថានភាពបច្ចុប្បន្ននិងស្ថានភាពរំពឹងទុកនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា



តាមរយៈរូបភាពបង្ហាញថា សមាសភាគនីមួយៗនៃស្ថានភាពបច្ចុប្បន្នសុទ្ធតែទាបជាងសមាសភាគនីមួយៗ នៃស្ថានភាពរំពឹងទុកកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដែលតម្លៃមធ្យមភាគសរុបរួមគឺខុសគ្នាចំនួន 1.44 នៃតម្លៃមធ្យមភាគ ស្មើនឹង 36.00% នៃតម្លៃសរុប បង្ហាញឱ្យឃើញថា វាជាតម្លៃគម្លាតមួយដែលគួរឱ្យចាប់អារម្មណ៍។ ***ដូច្នេះ គេអាចសន្និដ្ឋានបានថា ការអនុវត្តការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍នាពេលបច្ចុប្បន្នទាមទារឱ្យមានការធ្វើកំណែទម្រង់ដោយមានយុទ្ធសាស្ត្រជាក់លាក់ដើម្បីឈានដល់ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ។***

ខ.២. តម្រូវការអាទិភាពនៃកំណែទម្រង់ ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

ខ.២.១.ការវិភាគភាពខ្លាំង ភាពខ្សោយនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

ការវិភាគទិន្នន័យផ្ទៃក្នុងនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍នៃស្ថានភាពបច្ចុប្បន្ននិងស្ថានភាពដែលចង់បាននៅថ្ងៃអនាគត ត្រូវកំណត់ឡើងដោយរូបមន្ត PNI modified ។ តម្លៃធំបំផុតរបស់ PNI modified ត្រូវយកទៅដកជាមួយតម្លៃតូចបំផុតរបស់ PNI modified ហើយចែកនឹង 2 ។ ភាពខុសគ្នានៃតម្លៃកណ្តាលទាំងពីរត្រូវបានគេប្រើប្រាស់សម្រាប់កំណត់ក្រុម ដែលក្រុមនោះឱ្យឈ្មោះថាក្រុមដែលមានតម្រូវការចំបាច់ខ្ពស់ និងក្រុមដែលមានតម្រូវការចាំបាច់ទាប ។ ក្រុមដែលទទួលបានតម្លៃ PNI modified ខ្ពស់មានន័យថាជាក្រុមដែលមានភាពទន់ខ្សោយ(Weakness=W) នៅក្នុងកំណែ

ទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា និងផ្ទុយទៅវិញ ក្រុមដែលទទួលបានតម្លៃ PNI modified ទាបមានន័យថាជាក្រុមដែលមានភាពខ្លាំង (Strength=S) នៅក្នុងកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ។

ចេញពីតម្លៃនៃការវិភាគទិន្នន័យផ្ទៃក្នុង នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ នៃស្ថានភាពបច្ចុប្បន្ននិងស្ថានភាពដែលចង់បាននៅថ្ងៃអនាគត គេទទួលបានតម្លៃ PNI modified ស្ថិតនៅចន្លោះពី 0.36 ដល់ 0.46 ។ ដូច្នេះគេអាចកំណត់តម្លៃផ្ទៃក្នុងនៃការញែកក្រុម PNI modified ជាក្រុមខ្ពស់និងក្រុមទាបបានដូចខាងក្រោម៖

(0.46+0.36)÷2 = 0.41 ដែលជាតម្លៃកណ្តាល ដោយអាស្រ័យលើតម្លៃនេះគេអាចកំណត់ក្រុម PNI modified ខ្ពស់និងទាបដូចខាងក្រោម ៖

PNI modified ខ្ពស់មានតម្លៃចាប់ពី 0.46 ដល់ 0.41 ចំណែកក្រុម

PNI modified ទាបមានតម្លៃចាប់ពី 0.36 ដល់តម្លៃ 0.40

តាមរយៈនៃតម្លៃនេះគេអាចសន្មតបានថា PNI modified ជារួមនៃសមាសភាគនីមួយៗនៃកំណែទម្រង់ការគ្រប់គ្រង មត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាត្រូវបានកំណត់ក្នុងតារាងខាងក្រោមនេះ។

តារាង៣៖ តម្រូវការអាទិភាព ចំណុចខ្លាំង និងចំណុចខ្សោយនៃកំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

តម្រូវការចាំបាច់អាទិភាពនៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	PNI modified	លំដាប់	S/W
១. ស្វ័យភាព	0.46	1	W
២. រង្វាយតម្លៃការសិក្សា	0.36	4	S
៣. គណនេយ្យភាព	0.45	2	W
៤. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន	0.44	3	W
សរុបរួម	**0.43**		

តាមតារាង៣ គេសង្កេតឃើញថាមាសភាគនីមួយៗនៅក្នុងកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍បានបង្ហាញថាសមាសភាគស្វ័យភាពមានតម្លៃ PNI modified = 0.46 ដែលកំណត់ថាជាចំណុចខ្សោយនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ហើយតម្លៃ PNI modified = 0.45 នៃសមាសភាគគណនេយ្យភាពដែលកំណត់ថាជាចំណុចខ្សោយនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ តាមមកដោយតម្លៃ PNI modified = 0.44 នៃសមាសភាគការយកចិត្ត

ទុកដាក់ដល់គ្រូបង្រៀនដែលកំណត់ថាជាចំណុចខ្សោយនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ និងចុងក្រោយគឺតម្លៃ PNI modified = 0.36 នៃសមាសភាគរង្វាយតម្លៃការសិក្សាដែលកំណត់ថាជាចំណុចខ្លាំង តាមលំដាប់លំដោយ ។

រូបភាពទី១០៖ PNI modifiedនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា



ការស្រាវជ្រាវរកឃើញថា កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍មានតម្រូវការអាទិភាពដូចតទៅ៖ (១) ពង្រឹងស្វ័យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា (PNI modified = 0.46) (២) ពង្រឹងគណានេយ្យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា (PNI modified = 0.45) (៣) បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា (PNI modified = 0.44) និង (៤) ជំរុញរង្វាយតម្លៃសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា (PNI modified = 0.36)។

លទ្ធផលខាងលើនេះបញ្ជាក់ថា ការធ្វើកំណែទម្រង់វិស័យអប់រំពីលើចុះក្រោម (a top-down approach) ដូចជាការរៀបចំកម្មវិធីសិក្សាលម្អិត សៀវភៅគោលសិក្សា ងាយស្រួលក្នុងការអនុវត្ត តែមិនគ្រប់គ្រាន់ទេដើម្បីលើកកម្ពស់គុណភាពសេវាអប់រំកុមារតូច(Fullan, 2007)។ លើសពីនេះ គណានេយ្យភាពមានតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅតាមសាលាមត្តេយ្យសិក្សាសហគមន៍ ពិសេសគណានេយ្យភាពរបស់នាយកសាលា (Patrinos, Velez និង Wang; WB, 2013) ។

ខ.២.២. ការវិភាគកាលានុវត្តភាព និងការគំរាមកំហែងនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

ក្រោយពីបានវិភាគ និងកំណត់បច្ច័យផ្ទៃក្នុងនៃសមាសភាគកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីគុណភាពអប់រំកុមារតូចនៅកម្ពុជារួចមកអ្នកស្រាវជ្រាវបានវិភាគដើម្បីរកតម្លៃតម្រូវការអាទិភាព PNI modified ដែលបណ្តាលមកពី នយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យាដែលមានឥទ្ធិពលលើការធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ។

ចេញពីតម្លៃនៃការវិភាគទិន្នន័យបច្ច័យខាងក្រៅរបស់កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍នៃស្ថានភាពបច្ចុប្បន្ននិងស្ថានភាពដែលចង់បាននៅថ្ងៃអនាគត គេទទួលបានតម្លៃ PNI modified ស្ថិតនៅចន្លោះពី 0.23 ដល់ 0.36 ។ ដូច្នេះគេអាចកំណត់តម្លៃបច្ច័យខាងក្រៅនៃការញែកក្រុម PNI modified ជាក្រុមខ្ពស់និងក្រុមទាបបានដូចខាងក្រោម៖

(0.36+0.23)÷2 = 0.30 ដោយអាស្រ័យលើតម្លៃនេះគេអាចកំណត់ក្រុម PNI modified ខ្ពស់និងទាបដូចខាងក្រោម ៖

PNI modified ខ្ពស់មានតម្លៃចាប់ពី 0.36 ដល់ 0.31 ជាតម្លៃនៃការគំរាមកំហែង ចំណែកក្រុម PNI modified ទាបមានតម្លៃចាប់ពី 0.23 ដល់តម្លៃ 0.30 ជាតម្លៃឱកាស។ តាមរយៈនៃតម្លៃនេះគេអាចសន្និដ្ឋានបានថា PNI modified ជារួមនៃសមាសភាគនីមួយៗនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ត្រូវបានកំណត់ក្នុងតារាងខាងក្រោម

តារាង៤៖ PNI_modified បច្ច័យខាងក្រៅនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីគុណភាពអប់រំកុមារតូចនៅកម្ពុជា

កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅ កម្ពុជា	**បច្ច័យខាងក្រៅ**														
	នយោបាយ			**សេដ្ឋកិច្ច**			**សង្គមវប្បធម៌**			**បច្ចេកវិទ្យា**			**សរុប**		
	PNI	Or	O/T	PNI	Or	O/T	PNI	Or	O/T	PNI	Or	O/T	PNI	Or	O/T
១. ស្វ័យភាព	0.31	1	T	0.30	2	O	0.28	3	O	0.34	1	T	0.31	1	T
២. រង្វាយតម្លៃ	0.27	4	O	0.24	3	O	0.26	4	O	0.32	3	T	0.27	4	O
៣. គណនេយ្យភាព	0.31	1	T	0.33	1	T	0.33	2	T	0.26	4	O	0.31	1	T
៤. ការយកចិត្តទុកដាក់ចំពោះគ្រូបង្រៀន	0.31	1	T	0.23	4	O	0.36	1	T	0.34	1	T	0.31	1	T
សរុបរួម	**0.30**		**O**	**0.28**		**O**	**0.31**		**T**	**0.32**		**T**	**0.30**		**O**

ចំណាំ៖ PNI= PNI modified; Or =order; O =Opportunity; T =Treat

តាមតារាង៤ លទ្ធផលនៃការវិភាគទិន្នន័យដែលបង្ហាញពីបច្ច័យខាងក្រៅនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីគុណភាពអប់រំកុមារតូចដែលបច្ច័យផ្នែកសេដ្ឋកិច្ចដែលមានតម្លៃ PNI modified =0.28 ចំណែកបច្ច័យផ្នែកនយោបាយមានតម្លៃ PNI modified =0.30 និងបច្ច័យផ្នែកសង្គមវប្បធម៌ដែលមានតម្លៃ PNI modified =0.31 និងបច្ច័យផ្នែកបច្ចេកវិទ្យាដែលមានតម្លៃ PNI modified =0.32 តាមលំដាប់លំដោយ ។

រូបភាពទី១១ ៖ PNI_modified នៃបច្ច័យខាងក្រៅសម្រាប់សមាសភាគកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍



តាមរូបភាពទី១០ បានបង្ហាញថាតម្លៃសម្ព័ន្ធភាពនៃបច្ច័យខាងក្រៅរវាងស្ថិយភាព រង្វាយតម្លៃ គណនេយ្យភាព និងការយកចិត្តទុកដាក់ចំពោះគ្រូបង្រៀន ដែលមានជាមួយនយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យាបានបង្ហាញឱ្យឃើញថាតម្លៃ PNI modifiedស្ថិតនៅចន្លោះ 0.23 - 0.36 ដែលតម្លៃព្រែករវាងឱកាស និងការគំរាមកំហែងគឺជាតម្លៃ 0.30 ចុះក្រោមជាតម្លៃចន្លោះឱកាស ចំណែកតម្លៃដែលចាប់ផ្តើមពី 0.31 ឡើងទៅជាតម្លៃដែលកំណត់ថាជាការគំរាមកំហែង។

ខ.៣. អភិវឌ្ឍយុទ្ធសាស្ត្រ កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

បន្ទាប់ពីអ្នកស្រាវជ្រាវបានវិភាគរកនូវចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងរួច អ្នកស្រាវជ្រាវបានចាប់ផ្តើមកំណត់ជាផែនការយុទ្ធសាស្ត្រ កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាដែលបែងចែកតាម ០៣ដំណាក់កាលគឺ ៖ ***ទី១. អភិវឌ្ឍយុទ្ធសាស្ត្រដំណាក់កាលទី១ដោយការវិភាគ SWOT & TOWS ទី២.ពិនិត្យភាពត្រឹមត្រូវពីអ្នកជំនាញ និង ទី៣. ពិនិត្យភាពត្រឹមត្រូវដោយការពិភាក្សាក្រុម។***

របកគំហើញអនុញ្ញាតឱ្យអ្នកស្រាវជ្រាវរៀបចំ**យុទ្ធសាស្ត្រចំនួន ៤** និង**យុទ្ធសាស្ត្ររងចំនួន ១២** ព្រមទាំង**កិច្ចដំណើរការចំនួន ១៩៦ ចំណុច** ដើម្បីធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្ររង	**កិច្ចដំណើរការ**
១. ស្វ័យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា [ចំណុចខ្សោយ-ការគំរាមកំហែង (WT)]	
១.១ បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១.ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ សហការជាមួយក្រសួងមហាផ្ទៃរៀបចំសេចក្តីណែនាំស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយមានការចូលរួមពីមាតាបិតានិងអាជ្ញាធរមូលដ្ឋាន ▪ កំណត់ពីតួនាទី ភារកិច្ច របៀបរបបបំពេញការងាររបស់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីពង្រឹងស្វ័យភាពរបស់សាលារៀន ។
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ ផ្តល់ជំនួយបច្ចេកទេស វគ្គបណ្តុះបណ្តាលសមត្ថភាព និងជំនាញ ដល់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដូចជាស្វ័យភាពក្នុងការគ្រប់គ្រងសាលារៀន ការកៀរគរការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ដើម្បីពង្រឹងស្វ័យភាពរបស់សាលា។
	៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖ ▪ សហការជាមួយ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង-ស្រុក ខណ្ឌ ដើម្បីសម្របសម្រួលជាមួយរដ្ឋបាល ឃុំ-សង្កាត់ ក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ▪ ពិនិត្យតាមដាន និងតម្រង់ទិសការអនុវត្តការងាររបស់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីធានាបានស្វ័យភាពរបស់សាលារៀន។
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ▪ សម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រេច	កិច្ចដំណើរការ
	▪ ពិនិត្យតាមដាន និងចុះគាំទ្របច្ចេកទេសផ្ទាល់ដល់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ក្នុងការបំពេញការងារដើម្បីធានាបានស្ថិយភាពរបស់សាលារៀន។
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ ចេញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ តាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ ▪ ពិនិត្យតាមដានការអនុវត្តការងាររបស់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ រាយការណ៍សុំមតិយោបល់បន្ថែម និងស្នើសុំការគាំទ្របន្ថែមពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ក្នុងករណីចាំបាច់
	៦. គណៈកម្មការគ្រប់គ្រងសាលារៀន ៖ ▪ លើកកម្ពស់ភាពជាអ្នកដឹកនាំ ក្នុងការគ្រប់គ្រងសាលារៀន ▪ បែងចែកការកិច្ច និងការទទួលខុសត្រូវដល់ប្រធាន អនុប្រធាន និងសមាជិក ▪ រៀបចំ និងដឹកនាំការប្រជុំជាទៀងទាត់ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីពិនិត្យ តាមដាន ដំណើរការសាលារៀន ▪ សិក្សាពីតម្រូវការសាលារៀននិងការដាក់ចេញនូវវិធានការដើម្បីបំពេញតាមតម្រូវការរបស់សាលារៀន កសាងផែនការអភិវឌ្ឍសាលារៀន ផែនការការងារប្រចាំខែ ត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ▪ ប្រើប្រាស់ធនធានសាលារៀនអស់លទ្ធភាព រៀបចំបរិស្ថាន សុវត្ថិភាព សោភ័ណ្ឌភាពអនាម័យ សណ្តាប់ធ្នាប់ និង ល្បែងក្រៅថ្នាក់ ▪ ពិភាក្សារួមគ្នារវាងគណៈគ្រប់គ្រងសាលារៀន ជាមួយនឹងមាតាបិតា និងអាជ្ញាធរមូលដ្ឋានក្នុងការជួយបំពេញតម្រូវការ ធានាឱ្យសាលារៀនបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយជោគជ័យ ▪ រៀបចំប្រព័ន្ធទទួលព័ត៌មានត្រឡប់ពីគ្រូដើម្បីសិក្សាវាយតម្លៃគុណភាពអប់រំ ▪ ពង្រឹងកិច្ចសហការពហុវិស័យក្នុងការគាំពារ និងអប់រំកុមារ ▪ ស្រឡាញ់រាប់អាន និងលើកទឹកចិត្តគ្រូបង្រៀន។
១.២ ជំរុញការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	១. ក្រសួងអប់រំ យុវជន និងកីឡា៖ ▪ ត្រូវរៀបចំសេចក្តីណែនាំ ស្តីពីការលើកកម្ពស់ការចូលរួមរបស់មាតាបិតា និងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ដើម្បីរួមចំណែកក្នុងការពង្រឹងស្ថិយភាពរបស់សាលារៀន
	២. នាយកដ្ឋានអប់រំកុមារតូច៖ ▪ ផ្តល់ការប្រឹក្សានានា និងរៀបចំវគ្គបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពអ្នកពាក់ព័ន្ធក្នុងការជួយលើកកម្ពស់ការចូលរួមរបស់មាតាបិតា សហគមន៍ ក្នុងការគ្រប់គ្រងសាលារៀន ធ្វើឱ្យមានការផ្លាស់ប្តូរវប្បធម៌ និងបរិយាកាសនៅក្នុងសាលារៀន
	៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត៖ ▪ ត្រូវជួយគាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការលើកទឹកចិត្ត និងជំរុញការចូលរួមរបស់មាតាបិតា សហគមន៍ ក្នុងការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ៖ ▪ ជំរុញការចូលរួមរបស់មាតាបិតា សហគមន៍ក្នុងដំណើរការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ចូលរួមការសិក្សាពីតម្រូវការសាលារៀន និងការដាក់ចេញនូវវិធានការ ដើម្បីបំពេញតាមតម្រូវការរបស់សាលា ▪ ជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការកៀរគរសប្បុរសជន វិស័យឯកជន និងដៃគូអភិវឌ្ឍចូលរួមជួយអភិវឌ្ឍសាលារៀន
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ ចូលរួមក្នុងដំណើរការគ្រប់គ្រងសាលារៀន សិក្សាពីតម្រូវការសាលារៀន និងការដាក់ចេញនូវវិធានការ ដើម្បីបំពេញតាមតម្រូវការរបស់សាលា ▪ កៀរគរសហគមន៍ មាតាបិតា អ្នកអាណាព្យាបាល ចូលរួមក្នុងដំណើរការគ្រប់គ្រងសាលារៀន សិក្សាពីតម្រូវការសាលារៀន និងការដាក់ចេញនូវវិធានការឆ្លើយតបតម្រូវការពង្រឹងគុណភាពសេវាសាលាមត្តេយ្យសិក្សាស្របតាមគោលការណ៍ «ភាពជាដៃគូរដ្ឋនិងសហគមន៍ដើម្បីការអប់រំ» ▪ កៀរគរសហគមន៍ មាតាបិតា អ្នកអាណាព្យាបាល ចូលរួមធនធានរៀបចំបរិស្ថានបៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារឹម និងបរិក្ខារសិក្សា

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រេច	កិច្ចដំណើរការ
	៦. សាលារៀន៖ ▪ កៀរគរសហគមន៍ ចូលរួមសិក្សាពីតម្រូវការ និងមានវិធានការ ដើម្បីអភិវឌ្ឍសាលារៀន ▪ ត្រូវរៀបចំឱ្យមានការប្រជុំទៀងទាត់តាមផែនការ ជាមួយមាតាបិតាអ្នកអាណាព្យាបាលនិងសហគមន៍ ដែលមានការចូលរួមពីគណៈកម្មការគ្រប់គ្រងសាលារៀន ▪ រៀបចំអនុម័តផែនការកែលម្អ អភិវឌ្ឍន៍សាលាមត្តេយ្យសិក្សាសហគមន៍ និងលើកកម្ពស់ការសិក្សាកុមារ ▪ អនុវត្តផែនការអភិវឌ្ឍសាលារៀន ដោយផ្ទៀងផ្ទាត់ជាមួយលទ្ធផលសិក្សារបស់សិស្ស ពិសេសការកៀរគរធនធានដើម្បីជួយដល់សាលារៀនដើម្បីធានាបាននូវនិរន្តរភាព និងការអភិវឌ្ឍសាលារៀន ▪ ប្រជុំផ្សព្វផ្សាយអំពីដំណើរការ វឌ្ឍនភាពនិងបញ្ហាប្រឈមនានានៅក្នុងសាលាដល់សហគមន៍ ▪ បង្កើតកម្មវិធីជួបប្រជុំមាតាបិតា អ្នកអាណាព្យាបាល ទៅតាមប្រធានបទដូចជាការណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់អំពីហិង្សានៅក្នុងគ្រួសារ ការជំរុញការសិក្សារៀនសូត្រ សុវត្ថិភាពចំណីអាហារ .....។ល។ ▪ ចងក្រងក្រុមមាតាបិតា អ្នកអាណាព្យាបាលកុមារ និងប្រជុំជាមួយក្រុម ▪ មាតាបិតាផ្តោតលើកម្មវិធីអប់រំមាតាបិតាអំពីការចិញ្ចឹមបីបាច់ថែរក្សាកុមារតូច ▪ ចងក្រងក្រុមមាតាបិតាដែលមានកូនរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ និងប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម ដើម្បីពង្រីកទំនាក់ទំនងឆាប់រហ័ស ▪ ទទួលយកព័ត៌មានត្រឡប់យ៉ាងសកម្ម ពីសហគមន៍ និងភាគីពាក់ព័ន្ធ ▪ ស្នើសុំឱ្យមាតាបិតាជួយពិនិត្យតាមដានវត្តមាន និងពង្រឹងឥរិយាបថកុមារ ▪ ផ្សព្វផ្សាយការចុះឈ្មោះចូលរៀនរបស់កុមារតូចនៅដើមឆ្នាំសិក្សា
១.៣. លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់នាយក ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ **សហការជាមួយក្រសួងមហាផ្ទៃ រៀបចំសេចក្តីណែនាំ ដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការជ្រើសរើស និងតែងតាំង នាយកសាលាមត្តេយ្យសិក្សាសហគមន៍ ដោយនាយកសាលាម្នាក់គ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាលើសពីមួយថ្នាក់ ឬថ្នាក់មត្តេយ្យសិក្សាទាំងអស់នៅក្នុងឃុំ។**

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រេច	កិច្ចដំណើរការ
	២. នាយកដ្ឋានអប់រំកុមារតូច៖ ▪ ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ពីនីតិវិធីនៃការជ្រើសរើស និងតែងតាំង នាយកសាលាមត្តេយ្យសិក្សាសហគមន៍ ▪ ផ្តល់ការបណ្តុះបណ្តាលដល់នាយកសាលាមត្តេយ្យសិក្សាសហគមន៍ ពីការដឹកនាំគ្រប់គ្រងសាលា និងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់នាយក
	៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖ ▪ ផ្តល់ប្រឹក្សានានា និងចុះជួយគាំទ្រដល់ការដឹកនាំរបស់នាយកសាលាក្នុងការគ្រប់គ្រងសាលា ▪ ត្រូវសហការជាមួយការិយាល័យអប់រំ យុវជននិងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការបង្កើនភាពជាអ្នកដឹកនាំរបស់នាយកក្នុងការគ្រប់គ្រងសាលារៀន
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ៖ ▪ ចុះជួយគាំទ្រ តម្រង់ទិសការអនុវត្តក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់នាយកសាលាមត្តេយ្យសិក្សាសហគមន៍ ▪ ជ្រើសរើស និងប្រគល់ភារកិច្ចដល់មន្ត្រីណាម្នាក់ដែលមានបទពិសោធន៍ដឹកនាំ តម្រង់ទិស និងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ក្នុងក្រុង-ស្រុក ខណ្ឌរបស់ខ្លួន នៅពេលដែលសាលាមត្តេយ្យសិក្សាសហគមន៍មិនមាននាយក
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ ការជ្រើសរើស និងតែងតាំង នាយកសាលាមត្តេយ្យសិក្សាសហគមន៍ដោយនាយកសាលាម្នាក់គ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាលើសពីមួយថ្នាក់ ឬថ្នាក់មត្តេយ្យសិក្សាទាំងអស់នៅក្នុងឃុំ តាមគោលការណ៍ណែនាំរបស់ *ក្រសួងអប់រំ យុវជន និងកីឡា*
	៦. សាលារៀន ៖ ▪ បែងចែកតួនាទីឱ្យបានច្បាស់រវាងនាយកសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងការគ្រប់គ្រងសាលារៀន
	៧. នាយកសាលា ៖ ▪ ដឹកនាំការរៀបចំសូចនាករផលសម្រេច និងផែនការកែលម្អសាលារៀនដាក់ជូនគណៈកម្មការគ្រប់គ្រងសាលារៀនពិនិត្យសម្រេច

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	▪ ដឹកនាំការធ្វើស្វ័យវាយតម្លៃ ការអនុវត្តរបស់សាលារៀន ធៀបជាមួយនឹងស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ និងរាយការណ៍លទ្ធផលជូនគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីដាក់ចេញវិធានការកែលម្អចំណុចខ្វះខាត ▪ រៀបចំប្រជុំបច្ចេកទេសប្រចាំខែជាមួយគ្រូបង្រៀន និងបង្កលទ្ធភាពឱ្យគ្រូ និងគ្រូផ្លាស់ប្តូរបទពិសោធ និងចែករំលែកចំណេះដឹងទៅវិញទៅមក ▪ រៀបចំបញ្ជីកាគណនេយ្យហិរញ្ញវត្ថុ និងបញ្ជីសារពើភ័ណ្ឌ ដើម្បីបង្ហាញពីគណនេយ្យភាព និងតម្លាភាព ▪ ដឹកនាំរៀបចំបរិស្ថាន សុវត្ថិភាព សោភណភាព អនាម័យ និងសណ្តាប់ធ្នាប់ ▪ ប្រជុំត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា តាមដានការរៀននិងបង្រៀន និងស្វ័យវាយតម្លៃសាលារៀនជាប្រចាំ ▪ គ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និងវាយតម្លៃដាក់ស្នើផ្តល់រង្វាន់ដល់គ្រូដែលបានបំពេញការងារល្អប្រសើរឬស្នើដល់គណៈកម្មការគ្រប់គ្រងសាលារៀន នូវវិធានការកែលម្អសម្រាប់គ្រូបង្រៀនដែលមិនអនុវត្តភារកិច្ចបានត្រឹមត្រូវ ▪ រួមវគ្គបណ្តុះបណ្តាល និងបញ្ជូនគ្រូចូលរួមវគ្គបណ្តុះបណ្តាលការអប់រំកុមារ ▪ សម្របសម្រួលការពិភាក្សារវាងគណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតា និងអ្នកពាក់ព័ន្ធ និងធ្វើជាអាជ្ញាកណ្តាលក្នុងការផ្សះផ្សាទំនាស់ក្នុងសាលារៀន ▪ កៀរគរបង្កលក្ខណៈងាយស្រួលក្នុងការបំពេញបែបបទចូលរៀនរបស់កុមារគួច
២. បង្កើនគណនេយ្យភាពសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា [ចំណុចខ្សោយ-ការគំរាមកំហែង (WT)]	
២.១. ជំរុញការរៀបចំផែនការអភិវឌ្ឍសាលារៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា៖ ▪ រៀបចំសេចក្តីណែនាំនានា សម្រាប់ជំរុញដល់ការបង្កើតផែនការកែលម្អសាលាមត្តេយ្យសិក្សាសហគមន៍ ▪ ពង្រីកការទទួលស្គាល់គុណភាពអប់រំ តាមរយៈការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ស្តង់ដាទៅជា ឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	▪ រៀបចំយន្តការដើម្បីគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសហគមន៍ និងប្រែក្លាយទៅជាសាលាមត្តេយ្យសិក្សាសាធារណៈ ▪ រៀបចំយន្តការគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសាធារណៈឱ្យក្លាយជាសាលាមត្តេយ្យសិក្សាគំរូ
	២. នាយកដ្ឋានអប់រំកុមារតូចៈ ▪ ផ្តល់ប្រឹក្សាបច្ចេកទេសនានា រៀបចំវគ្គបណ្តុះបណ្តាលនៅក្នុងការបង្កើតផែនការកែលម្អសាលាមត្តេយ្យសិក្សាសហគមន៍ ▪ ចុះវាយតម្លៃគុណភាពអប់រំ និងលើកសំណើដើម្បីប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដាទៅជា ឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ▪ ចុះគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសហគមន៍ លើកសំណើដើម្បីប្រែក្លាយទៅជាសាលាមត្តេយ្យសិក្សាសាធារណៈ ▪ ចុះគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសាធារណៈ លើកសំណើដើម្បីប្រែក្លាយជាសាលាមត្តេយ្យសិក្សាគំរូ
	៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖ ▪ សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ និងនាយកដ្ឋានអប់រំកុមារតូចចុះគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសហគមន៍ ក្នុងការអនុវត្តផែនការកែលម្អសាលារៀន ដើម្បីប្រែក្លាយទៅជាសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ និងប្រែក្លាយទៅជាសាលាមត្តេយ្យសិក្សាគំរូ
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ៖ ▪ ចុះពិនិត្យ កែលម្អ ជំរុញការអនុវត្តផែនការកែលម្អសាលារៀន ពង្រឹងគុណភាពសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីប្រែក្លាយមត្តេយ្យសិក្សាសហគមន៍មានស្តង់ដា និងទៅជាមត្តេយ្យសិក្សារដ្ឋ។
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់៖ ▪ ចូលរួមជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន អនុម័តផែនការកែលម្អសាលារៀន ▪ ចូលរួមពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំផែនការកែលម្អសាលារៀន
	៦. សាលារៀន៖ ▪ រៀបចំផែនការកែលម្អសាលាមត្តេយ្យសិក្សាសហគមន៍ទាំងហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីអប់រំកុមារតូច

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	▪ រៀបចំទីធ្លាសម្រាប់កុមារលេងមានលក្ខណៈសមស្រប មានសុវត្ថិភាព និងសម្ភារៈល្បែងសិក្សា រៀបចំថ្នាក់រៀនឱ្យមានផាសុកភាព និងបរិយាកាសល្អ ▪ ធ្វើទំនើបកម្មលើបរិក្ខារូបវន្តសម្រាប់គ្រូបង្រៀនបំពេញការងារ និងរៀបចំថ្នាក់រៀនឱ្យមានសម្ភារៈគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យា ▪ អគារសិក្សា និងថ្នាក់រៀនត្រូវបានជួសជុល និងកែលម្អជាប្រចាំ ▪ ថែរក្សាអនាម័យក្នុងសាលារៀន និងសុវត្ថិភាពចំណីអាហារ ▪ រៀបចំបណ្តាញទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍនានា ដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ
២.២.បង្កើនគណនេយ្យភាពរបស់នាយកសាលា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ ចេញសេចក្តីណែនាំនានាសម្រាប់លើកកម្ពស់គណនេយ្យភាពរបស់នាយកសាលាមត្តេយ្យសិក្សាសហគមន៍
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ ត្រូវផ្តល់ប្រឹក្សាបច្ចេកទេសនានា រៀបចំវគ្គបណ្តុះបណ្តាលដល់នាយកសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីពង្រឹងអភិបាលកិច្ច និងជានានូវគណនេយ្យភាពក្នុងការគ្រប់គ្រងសាលារៀន
	៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖ ▪ សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការវាយតម្លៃ និងតម្រង់ទិសការបំពេញការងារ លើកកម្ពស់គណនេយ្យភាពរបស់នាយកសាលា
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ៖ ▪ ពិនិត្យលើការប្រើប្រាស់ថវិកាសាលារៀន ដែលត្រូវតែផ្តោតលើការងាររៀន និងបង្រៀន និងការផ្តល់សម្ភារៈបង្រៀន ការកែលម្អវិធីសាស្ត្រគរុកោសល្យ ការផ្តល់សេវាជួយសិស្ស ការកែលម្អបរិស្ថានថ្នាក់រៀននិងសាលារៀន ▪ ពិនិត្យលើការវាយតម្លៃលទ្ធផលសិក្សាសិស្ស និងការផ្តល់ព័ត៌មានពីលទ្ធផលសិក្សាសិស្សទៅមាតាបិតា
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ វាយតម្លៃការបំពេញការងាររបស់នាយកសាលា ធ្វើការណែនាំ កែលម្អចំណុចខ្វះខាត និងលើកសរសើរដល់នាយកដែលអនុវត្តការងារបានល្អ មានគណនេយ្យភាពខ្ពស់

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	៦. សាលារៀន ៖ ▪ ផ្សព្វផ្សាយជាសាធារណៈនូវការអនុវត្តថវិកាដំណើរការសាលា ▪ ផ្តល់ព័ត៌មានពីលទ្ធផលការសិក្សារបស់សិស្សដល់មាតាបិតា ▪ ធ្វើរបាយការណ៍លទ្ធផលការសិក្សា និងការអនុវត្តថវិកាដំណើរការសាលា ទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌនិងក្រុមប្រឹក្សាឃុំ-សង្កាត់ ▪ បិទផ្សាយជាសាធារណៈព័ត៌មានដែលបានអនុម័តដោយគណៈកម្មការគ្រប់គ្រងសាលារៀន
	៧. នាយកសាលា ៖ ▪ នាយកបំពេញការងារ តាមតួនាទី និងភារកិច្ច ដែលបានកំណត់ ▪ ផ្សព្វផ្សាយពីកិច្ចបញ្ជីការបស់សាលាមត្តេយ្យសិក្សាសហគមន៍ ▪ កត់ត្រាពីការប្រើប្រាស់ធនធានសមស្របនឹងការអភិវឌ្ឍសាលា និងទទួលយកមតិយោបល់កែលម្អលើការប្រើប្រាស់ធនធានសាលា ▪ លុបបំបាត់ទំនាស់ផលប្រយោជន៍របស់គ្រូ កើតមានឡើងនៅក្នុងសាលា ▪ កៀរគរធនធានគាំទ្រពីសហគមន៍ និងបង្កលទ្ធភាពឱ្យមានការចូលរួមសម្រេចចិត្ត និងការគាំទ្រពីភាគីពាក់ព័ន្ធនានា ▪ វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន ប្រកបដោយតម្លាភាព
២.៣.ពង្រឹងការកែលម្អ បរិស្ថានសិក្សាដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ បន្តវិនិយោគទៅលើការពង្រឹង និងពង្រីកសាលាមត្តេយ្យសិក្សារដ្ឋតាមគោលការណ៍បង្កើតមត្តេយ្យសិក្សាយ៉ាងតិចមួយបន្ទប់ នៅក្នុងសាលាបឋមសិក្សារដ្ឋមួយ ▪ បន្តសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ អាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំសាលាមត្តេយ្យសិក្សាសហគមន៍ឱ្យមានស្តង់ដា ▪ រៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ (M&E)ដើម្បីបញ្ចូលសាលាមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាឱ្យក្លាយទៅជាឧបសម្ព័ន្ធនៃបឋមសិក្សាឬមត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក ▪ រៀបចំ និងអនុម័តស្តង់ដាអគារសិក្សាសម្រាប់មត្តេយ្យសិក្សាសហគមន៍ដោយមានច្រើនជម្រើស(អគារឈើ អគារថ្ម មួយបន្ទប់ ឬពីរបន្ទប់...)

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រេច	កិច្ចដំណើរការ
	៣. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ បណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការអប់រំកុមារតូច នៅរាជធានី-ខេត្ត ដើម្បីពង្រឹងយន្តការM&E ▪ ផ្តល់ប្រឹក្សាបច្ចេកទេសនានា និងពង្រឹងការកែលម្អបរិស្ថានសិក្សាសម្រាប់មត្តេយ្យសិក្សាសហគមន៍
	២. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖ ▪ ពង្រឹងយន្តការM&E និងគាំទ្រដល់ការកែលម្អបរិស្ថានសិក្សា និងពង្រឹងគុណភាពនៃការផ្តល់សេវាមត្តេយ្យសិក្សាសហគមន៍ ▪ សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ បន្តកៀរគរធនធានតាមសហគមន៍ដើម្បីបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍តាមលទ្ធភាព
	៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ៖ ▪ ចុះពិនិត្យ ផ្តល់ការគាំទ្រដល់ការកែលម្អបរិស្ថានសិក្សា ដើម្បីកែលម្អលទ្ធផលសិក្សាសិស្ស ជាពិសេសបរិស្ថានហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈសិក្សា និងការរៀបចំបន្ទប់រៀន និងទីធ្លាលេ្បងសិក្សា
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ ជួយកៀរគរធនធានក្នុងការកែលម្អបរិស្ថានសិក្សា ដើម្បីកែលម្អលទ្ធផលសិក្សាសិស្ស
	៦. សាលារៀន ៖ ▪ កៀរគរធនធាន និងលើកកម្ពស់ការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការកែលម្អបរិស្ថានសិក្សា បង្កើតភាពជាម្ចាស់ និងចូលរួមក្នុងភាពជោគជ័យរបស់សាលា ▪ កែលម្អបរិស្ថានសាលារៀន ជាសាលារៀនបៃតង មានអនាម័យស្អាតជាប្រចាំ លេ្បងលេងក្រៅថ្នាក់សមស្រប និងមានសុវត្ថិភាព ថ្នាក់រៀនមានសង្ហារិមតាមស្តង់ដា ▪ រៀបចំទឹកស្អាតសម្រាប់កុមារញ៉ាំ និងទឹកប្រើប្រាស់សម្រាប់សាលា ▪ រៀបចំប្រអប់សង្គ្រោះបឋម និងតាមដានសុខភាពកុមារ ▪ បង្កើតទំនាក់ទំនងគណនេយ្យភាពរវាងគណៈគ្រប់គ្រងសាលារៀនជាមួយមាតាបិតា និងរវាងសាលារៀនជាមួយនឹងអាជ្ញាធរមូលដ្ឋាន

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្ររង	កិច្ចដំណើរការ
៣. បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា [ចំណុចខ្លាំង-ការគំរាមកំហែង (ST)]	
៣.១. ពង្រឹងការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា៖ ▪ ត្រូវបង្កើនចំនួនគ្រូមត្តេយ្យសិក្សា ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូ ដោយបណ្តុះបណ្តាលនិងធ្វើការផ្តល់អាជ្ញាបណ្ណសម្រាប់បំពេញតម្រូវការគ្រូមត្តេយ្យសិក្សាគ្រប់រូបភាព ▪ កំណត់លក្ខខណ្ឌ និងសេចក្តីណែនាំជាក់លាក់សម្រាប់ពង្រឹងការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អ ជាគ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍ ពិសេសសម្រាប់បង្រៀននៅមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ▪ រៀបចំប្រព័ន្ធលើកទឹកចិត្តដើម្បីទាក់ទាញអ្នកដែលមានសមត្ថភាពឱ្យចូលធ្វើគ្រូមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ▪ ស្នើសុំគោលការណ៍ទៅក្រសួងមុខងារសាធារណៈ ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យារបស់រដ្ឋ បង្រៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ ▪ រៀបចំយន្តការវាយតម្លៃ ទទួលស្គាល់គ្រូមត្តេយ្យសិក្សាសហគមន៍ ដែលមានបទពិសោធន៍
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ ផ្តល់ប្រឹក្សាបច្ចេកទេស ពង្រឹងការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀនសម្រាប់សាលាមត្តេយ្យសិក្សាសហគមន៍ ▪ ផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ជាប្រចាំ ដើម្បីពង្រឹងការយកចិត្តទុកដាក់ដល់គ្រូបង្រៀន
	៣. មន្ទីរអប់រំ យុវជន និងកីឡា៖ ▪ សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ពង្រឹងការជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀននៅសាលាមត្តេយ្យសិក្សាសហគមន៍
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ៖ ▪ ចូលរួមជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការជ្រើសរើសបេក្ខជនដែលមាន

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	លក្ខណសម្បត្តិល្អជាគ្រូបង្រៀន នៅសាលាមត្តេយ្យសិក្សាសហគមន៍ និងជូនរបាយការណ៍ទៅកាន់មន្ទីរអប់រំ យុវជន និងកីឡា
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ ជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ ដោយមានការចូលរួមពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ▪ លើកទឹកចិត្ត និងកៀរគរបេក្ខជនដែលមានលក្ខណសម្បត្តិល្អឱ្យចូលប្រឡងគ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍ ▪ ចុះកិច្ចសន្យាត្រឹមត្រូវជាមួយគ្រូបង្រៀនដែលបានជ្រើសរើស
៣.២.បង្កើនប្រាក់បៀវត្ស លើកទឹកចិត្តគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា៖ ▪ ពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំបង្កើនប្រាក់បៀវត្ស និងការលើកទឹកចិត្តនានាដល់គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ▪ សហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំបើកផ្តល់ប្រាក់បៀវត្សប្រចាំរៀងរាល់ខែ ដល់គ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ សម្របសម្រួលនីតិវិធីក្នុងការ បើកផ្តល់ប្រាក់បៀវត្សនិងការលើកទឹកចិត្តឱ្យបានទៀងទាត់ដល់គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ▪ ផ្តល់ការបណ្តុះបណ្តាល វគ្គបំប៉នបន្ថែមនានា ដល់គ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍ ▪ បង្កលក្ខណៈឱ្យមានការប្រកួតប្រជែងលើស្នាដៃអប់រំកុមារ និងផ្តល់បណ្ណសរសើរលើកទឹកចិត្តគ្រូដែលមានស្នាដៃល្អ
	៣. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ៖ ▪ លើកទឹកចិត្តដល់គ្រូបង្រៀន ចូលរួមក្នុងការសិក្សាស្រាវជ្រាវលើការអប់រំកុមារ ឬការស្រាវជ្រាវប្រតិបត្តិ ▪ លើកទឹកចិត្ត និងគាំទ្រគ្រូបង្រៀនក្នុងការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនកុមារ

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្ររង	កិច្ចដំណើរការ
	៤. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ ផ្តល់ថវិកាលើកទឹកចិត្តបន្ថែមដល់គ្រូមត្តេយ្យសិក្សាសហគមន៍ជាប់ស្តង់ដា ▪ ផ្តល់ប្រាក់បៀវត្ស និងការលើកទឹកចិត្តនានា ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ដែលមិនទាន់ជាប់ស្តង់ដា ▪ ឆ្លើយតបទាន់ពេលវេលាលើបញ្ហាប្រឈមនានារបស់គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍
	៥. សាលារៀន៖ ▪ ផ្តល់រង្វាន់លើកទឹកចិត្តគ្រូបង្រៀន ពេលរកឃើញវិធីសាស្ត្របង្រៀនថ្មីៗនិងប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនកុមារ ▪ កំណត់នូវចំនួនប្រាក់បៀវត្ស និងការលើកទឹកចិត្តនានា ដែលត្រូវផ្តល់ឱ្យគ្រូបង្រៀនម្នាក់ៗ ពេលរកឃើញវិធីសាស្ត្របង្រៀនថ្មីៗ ▪ លើកទឹកចិត្តដល់គ្រូបង្រៀនដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវលើការអប់រំកុមារ ឬការស្រាវជ្រាវប្រតិបត្តិ
៣.៣. ពង្រឹងការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ ធ្វើទំនើបកម្មសាលាមធ្យមសិក្សាគរុកោសល្យ ប្រែក្លាយទៅជាវិទ្យាស្ថានគរុកោសល្យមត្តេយ្យសិក្សា (ប្រព័ន្ធអប់រំឧត្តមសិក្សាដែលប្រើប្រាស់ក្រេឌីត ១២+៤) និងទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធផ្នែករឹងនិងទន់ (បង្កើនគុណវុឌ្ឍិគ្រូ ឧទ្ទេសឱ្យដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់) ▪ កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា និងពិនិត្យកែឯកសារបណ្តុះបណ្តាលនានា និងពិនិត្យកែលម្អវិធីសាស្ត្របង្រៀនមត្តេយ្យសិក្សា ដើម្បីឆ្លើយតបគោលដៅក្នុងការអប់រំអាកប្បកិរិយា បុគ្គលិកលក្ខណៈ ចរិយាធម៌ សិល្បៈ និងវប្បធម៌ ត្រៀមខ្លួនសម្រាប់យុទ្ធសាស្ត្រ និងចក្ខុវិស័យជាតិ ២០៥០
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ រៀបចំវគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ឱ្យមានស្តង់ដាយ៉ាងហោចណាស់សមមូលសញ្ញាបត្រមធ្យមសិក្សា ដោយបង្កើនរយៈពេលបណ្តុះបណ្តាលនិងឱ្យមានស្តង់ដា (ពី៣៥ថ្ងៃឡើងទៅ)

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	▪ ផ្តល់ការបំប៉នដំបូងតាមស្តង់ដារយៈពេល៣៥ថ្ងៃ ដល់គ្រូមត្តេយ្យសិក្សា សហគមន៍ពីការងាររដ្ឋបាលសាលារៀន បច្ចេកទេស និងការផលិតសម្ភារៈឧបទេសសម្រាប់រៀន និងបង្រៀន ▪ ផ្តល់ការបណ្តុះបណ្តាលជំនាញប្រឹក្សាគរុកោសល្យកុមារតូច និងជំនាញទំនាក់ទំនងអន្តរបុគ្គល ដល់គ្រូមត្តេយ្យសិក្សាសហគមន៍
	៣. មន្ទីរអប់រំ យុវជន និងកីឡា ៖ ▪ សហការជាមួយអាជ្ញាធររាជធានី-ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ខណ្ឌ រៀបចំកម្មវិធីបណ្តុះបណ្តាលមាតាបិតា អ្នកអាណាព្យាបាលផ្សារភ្ជាប់មត្តេយ្យសិក្សាសហគមន៍ ពីសារៈសំខាន់នៃ១០០០ថ្ងៃដំបូង និងការចិញ្ចឹមបីបាច់កូនឱ្យបានត្រឹមត្រូវ ▪ ប្រមូល និងបូកសរុបតម្រូវការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ ជូនក្រសួងអប់រំ យុវជន និងកីឡា
	៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ខណ្ឌ ៖ ▪ ចុះគាំទ្រការប្រជុំបច្ចេកទេស និងធ្វើថ្នាក់និទស្សន៍ តាមមុខវិជ្ជាដែលត្រូវបង្រៀនដល់ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ ▪ លើកតម្រូវការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ ជូនមន្ទីរអប់រំ យុវជន និងកីឡា
	៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖ ▪ កៀរគរមាតាបិតាចូលរួមកម្មវិធីបណ្តុះបណ្តាលមាតាបិតា ផ្សារភ្ជាប់មត្តេយ្យសិក្សាសហគមន៍
	៦. សាលារៀន ៖ ▪ ផ្តល់ឱកាសដល់គ្រូបង្រៀនបានអភិវឌ្ឍជំនាញក្នុងការបង្រៀន និងរង្វាយតម្លៃផ្នែកគាំពារ និងអប់រំកុមារជាប់ជាប្រចាំ ▪ លើកទឹកចិត្តដល់គ្រូមត្តេយ្យសិក្សាសហគមន៍ក្នុងការចូលរួមការសិក្សាស្រាវជ្រាវ ដោយជំរុញបរិបទនៃការសិក្សាដោយខ្លួនឯង
៤. ជំរុញរង្វាយតម្លៃសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា [ចំណុចខ្លាំង-ឱកាស (SO)]	
៤.១. បង្កើនការផលិតនិងប្រើប្រាស់កម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ កែលម្អកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍ដោយដាក់បញ្ចូល

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្ររង	កិច្ចដំណើរការ
	ភាពធន់នឹងបម្រែបម្រួលអាកាសធាតុ និងការជួយថែរក្សាបរិស្ថាន ការរៀនតាមរយៈការលេង រឿងនិទាន ការផលិតសម្ភារៈឧបទេស រង្វាយតម្លៃសិក្សាសម្រាប់សាលាមត្តេយ្យសិក្សាសហគមន៍ .....។ល។ ▪ រៀបចំសេចក្តីណែនាំនានាស្តីពីការអនុវត្តកម្មវិធីសិក្សាលម្អិត និងសៀវភៅគ្រូសម្រាប់មត្តេយ្យសិក្សាសហគមន៍
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ បណ្តុះបណ្តាលការអនុវត្តកម្មវិធីអប់រំកុមារតូច និងការប្រើប្រាស់សៀវភៅគ្រូ ការផលិតសម្ភារៈឧបទេស ការអនុវត្តរង្វាយតម្លៃសិក្សាដល់គ្រូមត្តេយ្យសិក្សាសហគមន៍
	៣. មន្ទីរអប់រំ យុវជន និងកីឡាត្រូវ៖ ▪ សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ជំរុញ និងគាំទ្រការអនុវត្តកម្មវិធីសិក្សាលម្អិត និងការប្រើប្រាស់សៀវភៅគ្រូ ការផលិតសម្ភារៈឧបទេស និងរង្វាយតម្លៃសិក្សាសិស្សមត្តេយ្យសិក្សាសហគមន៍ ឱ្យបានត្រឹមត្រូវ ▪ ប្រមូល និងបូកសរុបលទ្ធផលរង្វាយតម្លៃសិក្សាសិស្សសាលាមត្តេយ្យសិក្សាសហគមន៍ រាយការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់ចេញវិធានការឆ្លើយតប
	៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ៖ ▪ ពង្រឹង និងកែលម្អ ការអនុវត្តកម្មវិធីសិក្សាលម្អិត និងការប្រើប្រាស់សៀវភៅគ្រូ ការផលិតសម្ភារៈឧបទេស ព្រមទាំងរង្វាយតម្លៃសិក្សាសិស្សមត្តេយ្យសិក្សាសហគមន៍ និងធ្វើរបាយការណ៍ជូនមន្ទីរអប់រំ យុវជន និងកីឡា
	៥. សាលារៀន ៖ ▪ មានសៀវភៅសិក្សា សម្ភារៈបង្រៀន និងរៀន ឆ្លើយតបនឹងតម្រូវការគ្រូនិងកុមារតូច ▪ រៀបចំបរិស្ថានសាលារៀន ថ្នាក់រៀន និងទីធ្លាលេងខាងក្រៅសមស្រប និងមានសុវត្ថិភាពសម្រាប់កុមារ ▪ ស្នើសុំការគាំទ្រធនធាន បច្ចេកទេសបន្ថែម ទៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ខណ្ឌនិងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងគោលបំណងធានាបាននូវគុណភាពអប់រំកុមារតូចនៅកម្ពុជា។

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រទ	កិច្ចដំណើរការ
	៦. គ្រូបង្រៀន ៖ ▪ មានបែងចែកមេរៀន និងចំនួនម៉ោងច្បាស់លាស់ ស្របតាមកម្មវិធីសិក្សាលម្អិតសម្រាប់សាលាមត្តេយ្យសិក្សាសហគមន៍ និងធ្វើបច្ចុប្បន្នភាពជាប្រចាំលើការអនុវត្តកម្មវិធីសិក្សា ▪ មានរៀបចំកិច្ចតែងការបង្រៀន សៀវភៅគ្រូ និងបញ្ជីផ្សេងៗ ▪ ការបង្រៀន និងរៀន បានអនុវត្តកម្មវិធីសិក្សាស្របតាមការអភិវឌ្ឍរាងកាយ អាយុ និងវប្បធម៌របស់កុមារ ▪ ការបង្រៀន និងរៀន មានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ ▪ មានទំនាក់ទំនងជាមួយអ្នកអាណាព្យាបាល ក្នុងការបង្កើតថ្នាក់រៀននៅផ្ទះ ដើម្បីគាំទ្របរិយាកាសសិក្សារបស់កុមារ ▪ បានកត់ត្រា និងតាមដានពីការរៀនសូត្រ ការអភិវឌ្ឍបញ្ញា ការគិត រាងកាយ និងសកម្មភាពរបស់កុមារ ក្នុងសៀវភៅការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ
៤.២. បង្កើតវិធីសាស្ត្ររៀន និងបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ កំណត់លក្ខខណ្ឌជាក់លាក់ មគ្គុទ្ទេសក៍ត្រឹមត្រូវ ឬសេចក្តីណែនាំនានា សម្រាប់អនុវត្តវិធីសាស្ត្ររៀន និងបង្រៀនដល់គ្រូមត្តេយ្យសិក្សាសហគមន៍ ▪ បញ្ចូលវិធីសាស្ត្របង្រៀនថ្មីៗ ក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យ
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ ផ្តល់ការបណ្តុះបណ្តាលវិធីសាស្ត្ររៀន និងបង្រៀនថ្មីៗរបស់គ្រូមត្តេយ្យសិក្សាសហគមន៍
	៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖ ▪ ផ្តល់ការគាំទ្របច្ចេកទេស និងពង្រឹងការអនុវត្តវិធីសាស្ត្ររៀន និងបង្រៀនថ្មីៗ នៅតាមសាលាមត្តេយ្យសិក្សាសហគមន៍
	៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ខណ្ឌ ៖ ▪ ចុះត្រួតពិនិត្យ កែលម្អ ការអនុវត្តវិធីសាស្ត្ររៀននិងបង្រៀនរបស់គ្រូមត្តេយ្យសិក្សាសហគមន៍ ▪ បង្កើតការសិក្សាដកស្រង់បទពិសោធបច្ចេកទេសបង្រៀន និងរៀនតាម រយៈកម្មវិធីប្រឹក្សាគរុកោសល្យជាមួយគ្រូនិងគ្រូ រវាងគ្រូនិងនាយកសាលា ដែលមកពីមត្តេយ្យសិក្សាសហគមន៍នៅក្នុងឃុំជាមួយគ្នា ឬមកពីឃុំផ្សេងៗ នៅក្នុងក្រុង-ស្រុក

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្ររង	កិច្ចដំណើរការ
	៥. សាលារៀន ៖ ▪ ផ្តោតការយកចិត្តទុកដាក់លើដំណើរការបង្រៀននិងរៀន ដោយគ្រូបង្រៀនត្រូវចេះនិងអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ គឺការរៀនតាមរយៈការលេង ការសិក្សាតាមបែបគម្រោង និងការរៀនសម្របតាមសមត្ថភាពកុមារ ដោយឈរលើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ▪ លើកទឹកចិត្តគ្រូបង្រៀនក្នុងការប្រើបច្ចេកវិទ្យាជួយដល់ការបង្រៀននិងរៀន ▪ កំណត់របបប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំ ដោយសាលារៀននិងថ្នាក់រៀនដំណើរការស្របតាមនិយាមម៉ោងកំណត់ត្រឹមត្រូវដោយកាត់បន្ថយការបិទទ្វារ សាលារៀនមិនប្រក្រតី អវត្តមានគ្រូ និងអវត្តមានកុមារ។ ▪ សាលារៀនត្រូវផ្តោតការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា ដោយបង្កើតកម្មវិធីសិក្សាបន្ថែម ដូចជាកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំនៅសាលាបឋមសិក្សា ឬតំបន់ផ្សេងៗ សកម្មភាពទាំងនេះត្រូវដាក់បញ្ចូលក្នុងផែនការប្រចាំឆ្នាំរបស់សាលា ▪ បង្កើតកម្មវិធីការអប់រំសីលធម៌ និងចរិយាធម៌ ដើម្បីជួយគាំទ្រការអប់រំកុមារ ក្នុងនោះសាលាត្រូវរៀបចំប្រធានបទសិក្សាដែលទាក់ទងការបណ្តុះទម្លាប់កុមារឱ្យចេះសំពះ ចេះគួរសម ការប្រើពាក្យសំដីសមរម្យជាមួយអ្នកដទៃ ▪ អនុវត្តការអប់រំចិត្តសង្គមកុមារ ការអប់រំផ្លូវចិត្តមាតាបិតា អ្នកអាណាព្យាបាល តាមកម្មវិធីអប់រំរបបពុទ្ធសាសនា ▪ រៀបចំកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់ជាមួយមតេ្តយ្យសិក្សាសហគមន៍ ▪ ផ្តល់កញ្ចប់សម្ភារៈដល់ឪពុកម្តាយបង្គោលដើម្បីបន្តបណ្តុះបណ្តាលដល់មាតាបិតានិងអ្នកអាណាព្យាបាលអំពីការគាំពារកុមារតូច ▪ សាលាត្រូវបង្ហាញទេពកោសល្យកុមារ និងមាតាបិតា នៅក្នុងព្រឹត្តិការណ៍សំខាន់ៗរបស់សាលាប្រចាំឆ្នាំ ដើម្បីទាក់ទាញចំណាប់អារម្មណ៍ និងការចូលរួមសកម្មភាពរបស់មាតាបិតា អ្នកអាណាព្យាបាល ក្នុងការជួយគាំទ្រការរៀន និងបង្រៀនកុមារតូច ▪ កំណត់តួនាទី ភារកិច្ចជាក់លាក់ដល់គ្រូបង្រៀនក្នុងការប្រើប្រាស់វិធីសាស្ត្ររៀននិងបង្រៀនរបស់គ្រូ ក្នុងគោលបំណងធានាបាននូវរង្វាយតម្លៃសិក្សារបស់សិស្ស ឆ្ពោះទៅគុណភាពអប់រំកុមារតូចនៅកម្ពុជា។

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រេច	កិច្ចដំណើរការ
	៦. គ្រូបង្រៀន ៖ ▪ រៀបចំជ្រុងថ្នាក់រៀនស្របតាមស្តង់ដា ▪ អនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនចម្រុះ ដើម្បីកុមារទទួលបានការផ្តោតលើមេរៀន ▪ ស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ ចេះច្នៃប្រឌិតបង្កើតសម្ភារៈថ្មីៗសម្រាប់បង្រៀនកុមារតូច ▪ ជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ ហើយកុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង ▪ មានសមត្ថភាពអាចសម្រេចចិត្តលើដំណើរការបង្រៀននិងរៀនរបស់កុមារ ▪ ប្រើបច្ចេកវិទ្យាជួយក្នុងការបង្រៀននិងរៀន និងដើម្បីផ្តល់កិច្ចគាំទ្រដល់សកម្មភាពសិក្សារបស់កុមារ ▪ លើកសរសើរ និងផ្តល់កម្លាំងចិត្តដល់កុមារឱ្យមានភាពជឿជាក់លើខ្លួនឯង ▪ វាយតម្លៃលើការអភិវឌ្ឍការសិក្សារបស់កុមារ និងបានយកលទ្ធផលរង្វាយតម្លៃទៅរៀបចំផែនការបង្រៀនក្នុងខែ ឬត្រីមាសបន្ទាប់
៤.៣. ផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្ស ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា	
	១. ក្រសួងអប់រំ យុវជន និងកីឡា ៖ ▪ កំណត់លក្ខខណ្ឌជាក់លាក់ មគ្គទេសក៍ត្រឹមត្រូវ ឬសេចក្តីណែនាំនានាក្នុងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្ស មត្តេយ្យសិក្សាសហគមន៍
	២. នាយកដ្ឋានអប់រំកុមារតូច ៖ ▪ ផ្តល់ការបណ្តុះបណ្តាល ពីការវាយតម្លៃ និងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្សមត្តេយ្យសិក្សាសហគមន៍ ដោយជៀសវាងពីការផ្សព្វផ្សាយជាសាធារណៈ
	៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ៖ ▪ ផ្តល់ការគាំទ្របច្ចេកទេស និងពង្រឹងការអនុវត្តនីតិវិធីនៃការវាយតម្លៃលទ្ធផលសិក្សាសិស្ស និងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាល

យុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រេច	កិច្ចដំណើរការ
	៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ខណ្ឌ ៖ ▪ ចុះត្រួតពិនិត្យ កែលម្អ ការអនុវត្តរបស់សាលារៀនក្នុងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្សដោយផ្ទាល់ ដោយមិនធ្វើការផ្សព្វផ្សាយជាសាធារណៈ ▪ បូកសរុប និងផ្តល់របាយការណ៍ពីលទ្ធផលសិក្សាសិស្សជូនមន្ទីរអប់រំ យុវជន និងកីឡា
	៥. សាលារៀន ៖ ▪ កត់ត្រាលទ្ធផលសិក្សារបស់កុមារក្នុងសៀវភៅតាមដានការសិក្សាទៀងទាត់ ▪ ផ្តល់ព័ត៌មានពីលទ្ធផលសិក្សារបស់កុមារ ជូនមាតាបិតា និងអ្នកអាណាព្យាបាលទៀងទាត់ ដោយមិនធ្វើការផ្សព្វផ្សាយជាសាធារណៈ ▪ បង្កើតប្រព័ន្ធទំនាក់ទំនងនានាជាមួយមាតាបិតា និងអ្នកអាណាព្យាបាលកុមារ ជាមួយគណៈគ្រប់គ្រងសាលា ▪ ផ្តល់ព័ត៌មានដល់មាតាបិតា ដោយផ្អែកលើលទ្ធផលការតាមដានការលូតលាស់របស់កុមារ ▪ ផ្តល់ព័ត៌មានទៅអាជ្ញាធរពីករណីសង្ស័យថាកុមារមានអំពើហិង្សា ▪ រៀបចំគ្រូជួបដោយឡែក ជាមួយអ្នកអាណាព្យាបាល លើឥរិយាបថអសកម្មនានារបស់កុមារតូច ▪ ប្រើប្រាស់ទិន្នន័យពីលទ្ធផលសិក្សារបស់កុមារ ដើម្បីរៀបចំផែនការថ្នាក់រៀន និងសកម្មភាពសាលារៀន ▪ រៀបចំផែនការគាំទ្រលើការអភិវឌ្ឍយឺតរបស់កុមារដោយឈរលើលទ្ធផលសិក្សា និងដោយមានការចូលរួមពីមាតាបិតា និងសហគមន៍ ▪ តាមដានសមត្ថភាពកុមារចេញពីមត្តេយ្យ ទៅបន្តការសិក្សានៅថ្នាក់ខ្ពស់ៗ

ផ្នែកទី៤៖. សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ ជាពិសេស ***«យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១»*** ដែលរាជរដ្ឋាភិបាលនីតិកាលទី៧ បានដាក់ចេញ ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលារៀនមត្តេយ្យសិក្សា គឺជាធាតុសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវាអប់រំកុមារតូច ជានាបាននូវពង្រីកសេវាអប់រំកុមារមានគុណភាព សមធម៌ និងបរិយាបន្ន។ ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ជានាឱ្យបាននូវការអប់រំប្រកបដោយសមធម៌។ ក្នុងន័យនេះចាំបាច់ត្រូវមានផែនការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ ឱ្យក្លាយទៅជាសាលាមត្តេយ្យសិក្សាសហគមន៍មាន

ស្តង់ដានិងមានស្តង់ដាពេញលេញ ការប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍មានស្តង់ដាពេញលេញឱ្យទៅជាសាលាបណ្តាញនៅក្នុងសាលាកម្រង ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស ធ្វើឱ្យមានការផ្លាស់ប្តូរនូវវប្បធម៌ និងបរិយាកាសនៅក្នុងសាលារៀនគោលដៅនៃការគ្រប់គ្រងសាលារៀនមត្តេយ្យសិក្សាសហគមន៍។ ក្រសួងអប់រំ យុវជន និងកីឡាត្រូវពង្រឹងការធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយប្រើប្រាស់វិធីសាស្ត្រ *« ការគ្រប់គ្រងតាមសាលារៀនតាមប្រព័ន្ធបីអា 3As បិទជិត៖ (១). ស្ម័យភាព (២). គណនេយ្យភាព និង (៣). ការវាយតម្លៃ»*។

ទន្ទឹមនឹងនេះ គេត្រូវយកចិត្តទុកដាក់ លើការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ គ្រូដែលមានការអប់រំតាមវិជ្ជាជីវៈនៃការអប់រំកុមារតូច គឺជាកត្តាចម្បងនៃការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងជួយដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងបំណិនសង្គមរបស់កុមារតូច។ គ្រូបង្រៀនមិនត្រឹមតែមានគុណវុឌ្ឍិខ្ពស់ប៉ុណ្ណោះទេ តែត្រូវមានសមត្ថភាពនៅក្នុងការបង្កើតបរិស្ថានគរុកោសល្យ ដែលមានគុណភាពខ្ពស់។ ***គរុកោសល្យមានគុណភាពគឺ៖ ១.យល់ពីការអភិវឌ្ឍកុមារតូច ២.អន្តរកម្ម រវ៉ាមានរវាងគ្រូនិងសិស្ស ៣.ភាពជាអ្នកដឹកនាំដោះស្រាយបញ្ហានិងការរៀបចំកិច្ចតែងការ ៤. សមត្ថភាពបង្កើតបរិស្ថានការងារប្រកបដោយប្រសិទ្ធភាព។***

សរុបមកការគាំពារនិងអប់រំកុមារតូច គឺជាមូលដ្ឋាននៃការអភិវឌ្ឍសុខុមាលភាព និងសុខភាពរយៈពេលវែងរបស់កុមារ។ ការគាំពារនិងអប់រំកុមារតូចគឺជាសសរគ្រឹះសម្រាប់ការសិក្សាពេញមួយជីវិតតាមរយៈ ការកសាងនូវសមត្ថភាព និងបំណិន ដែលផ្តល់លទ្ធភាពឱ្យមនុស្សអាចសិក្សារៀនសូត្រពេញមួយជីវិត និងរកចំណូលសម្រាប់ទ្រទ្រង់ជីវភាពរបស់ខ្លួន។ ការវិនិយោគលើកុមារតូច យើងនឹងទទួលបានមកវិញនូវប្រយោជន៍ផ្សេងៗដូចជា៖ ប្រជាជនដែលមានសុខភាពល្អ និងមានគំនិតច្នៃប្រឌិតថ្មីមានទឹកចិត្តខ្ពស់ក្នុងការរួមចំណែកធំធេង ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ធ្វើឱ្យអនាគតរបស់យើងកាន់តែល្អប្រសើរ។

គោលនយោបាយដែលយើងជ្រើសរើស នឹងក្លាយជាកត្តាកំណត់ពីអនាគតនៃកុមារតូច និងសង្គមរបស់យើង។ ដូចនេះ កម្ពុជាចាំបាច់ត្រូវតែវិនិយោគលើការគាំពារ និងអប់រំកុមារតូច ដើម្បីកសាងមូលធនមនុស្សដែលមានសារៈសំខាន់ក្នុងការជួយឱ្យសម្រេចបាននូវចក្ខុវិស័យកម្ពុជា២០៥០ និងការដោះស្រាយនូវភាពក្រីក្រនិងបញ្ហាលំបាកផ្សេងៗ។

ខុងជឺធ្លាប់និយាយថា៖ *« ប្រសិនបើអ្នកមានផែនការរយៈពេល ១០០ ឆ្នាំ សូមអប់រំកុមារ!»*

យើងដឹងថាកុមារគឺជាអនាគតរបស់យើង *« តើយើងចង់បានអនាគតប្រភេទណា សម្រាប់កុមារកម្ពុជា ?»*

សូមអរគុណ!

ឯកសារយោង

Bruns, B., D. Filmer and H. A. Patrinos. (2011). *Making Schools Work: New Evidence on Accountability Reforms*. Washington DC: World Bank.

Clark, H., Coll-Seck, A. M., Banerjee, A., Peterson, S., Dalglish, S. L., Ameratunga, S., ... & Costello, A. (2020). A future for the world's children? A WHO–UNICEF–Lancet Commission. *The Lancet*, *395*(10224), 605-658.

De Bortoli, L., Underwood, C., & Thomson, S. (2023). PISA in Brief 2022: Student performance and equity in education.

Engle, P.L., L.C.H. Fernald, H. Alderman, J. Behrman, C. O'Gara, A. Yousafzai, M. Cabral de Mello, M. Hidrobo, N. Ulkuer, I. Ertem, S. (2011). Iltus and the Global Child Development

Erickson, K. I., Hillman, C. H., & Kramer, A. F. (2015). Physical activity, brain, and cognition. *Current opinion in behavioral sciences*, *4*, 27-32.

Elmore, R. F. (2000). *Building a New Structure for School Leadership*. Washington, DC: Albert Shanker Institute.

Evans, G. W. (2006). Child development and the physical environment. *Annual review of psychology*, *57*, 423.

Fullan, M. (2007). *The new meaning of educational change*: Routledge.

Glewwe, P. (2014). Education policy in developing countries: University of Chicago Press.

Gangan, F. Y., Batugal Jr, V., Sablay, A. F. R., Tullao Jr, T. S., & Yu, K. (2024). Educational Achievement Inequality in Southeast Asia Primary Learning Metrics (SEA-PLM) 2019 Participating Countries.

Goelman, H., Forer, B., Kershaw, P., Doherty, G., Lero, D., & LaGrange, A. (2006). Towards a predictive model of quality in Canadian child care centers. *Early Childhood Research Quarterly*, *21*(3), 280-295.

Glewwe, P. (2014). *Education policy in developing countries*: University of Chicago Press.

Guskey, T. R. (2000). *Evaluating professional development*: Corwin press.

Hanushek, E. A. and S. G. Rivkin. (2003). *How to Improve the Supply of High Quality Teachers?* Paper Prepared for the Brookings Papers on Education Policy.

Heckman, J. J. (2000). *Policies to foster human capital*. Research in economics, 54(1), 3-56.

Hoy, W., & Miskel, C. (2008). *Educational administration: theory, research, and practice. 8th edition*. New York: McGraw-Hill.

Hurley, K. M., Yousafzai, A. K., & Lopez-Boo, F. (2016). *Early child development and nutrition:* A review of the benefits and challenges of implementing integrated interventions.

រាជរដ្ឋាភិបាលកម្ពុជា, (២០២៣). *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ៖ ដើម្បីកំណើនការងារសមធម៌ ប្រសិទ្ធភាព និងចីរភាព*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤). *ផែនការសកម្មភាពស្តីពី ការគាំពារនិងអភិវឌ្ឍកុមារតូច ២០១៤ ដល់២០១៨ គ.ជ.គ.ក.*

ក្រសួងអប់រំ យុវជន និងកីឡា (២០២៥). *របាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា ២០២៤-២០២៥*

ក្រសួងអប់រំ យុវជន និងកីឡា (២០២៤). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០២៤-២០២៨*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧). *គោលការន៍ណែនាំស្តីពី ការគ្រប់គ្រងតាមសាលារៀន*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩). *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤*

ក្រសួងអប់រំ យុវជន និងកីឡា (២០២១). *សេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន*

Mourshed, M., Chijioke, C., & Barber, M. (2010). *How the world's most improved School systems keep getting better*. http://mckinseyonsociety.com.

Naron, H.C., (2020). *កំណែទម្រង់សាលារៀននៅកម្ពុជា*

គណកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតី (2020). *សៀវភៅណែនាំស្តីពី ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍សម្រាប់ ឃុំ សង្កាត់*

National Committee for Sub-National Democratic Development (2020). *មេរៀនបទពិសោធន៍ល្អៗមួយចំនួនដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ*

Patrinos, H. A., Velez, E., & Wang, C., Y. (2013). *Framework for the Reform of Education Systems and Planning for Quality*. The World Bank, Human Development Network, Education Unit. WB.

Snoek, M. (2021). Educating quality teachers: How teacher quality is understood in the Netherlands and its implications for teacher education. *European Journal of Teacher Education*, *44*(3), 309-327.

Taguma, M., Litjens, I., & Makowiecki, K. (2012). *Quality Matters in Early Childhood Education and Care: Finland*. OECD Publishing. 2, rue Andre Pascal, F-75775 Paris Cedex 16, France.

UNESCO (2006). *Education for All global* monitoring report 2007: Strong Foundations. Paris: UNESCO.

UNICEF. (2018). *A statistical profile of child protection in Cambodia.*

World Health Organization. (2018). *Nurturing care for early childhood care and development: A framework for helping children survive and thrive to transform health and human potential*. Switzerland: World Health Organization. Retrieved from https://iris.who.int/bitstream/handle/10665/272603/9789241514064-eng.pdf?sequence=1.

World Bank (2010). *Stepping up Skills: For more jobs and higher productivity*. Washington D.C.: World Bank.

World Bank (2018). *LEARNING to Realize Education's Promise*: The World Development Report. Washington D.C.: World

Yoshikawa, H., Weiland, C., Brooks-Gunn, J., Burchinal, M. R., Espinosa, L. M., Gormley, W. T., ... & Zaslow, M. J. (2013). *Investing in our future: The evidence base on preschool education.*

Zhang, L. F. (2006). Does student–teacher thinking style match/mismatch matter in students′ achievement? *Educational psychology*, *26*(3), 395-409.